ឈ្មោះគំរោង កម្ពុជា (KH) -ការគ្រប់គ្រងដីធ្លីនិង...@ គំរោងរដ្ឋបាល

តំបន់ អាស៊ីខាងកើត និងតំបន់ប៉ាស៊ីហ្វិច

ផ្នែក អភិវឌ្ឍស្ថាបន្យ គ្រប់គ្រងធនធានធម្មជាតិ

គំរោងលេខ KHPE70875

អ្នកខ្ចី ព្រះរាជាណាចក្រកម្ពុជា

ទីភ្នាក់ងារអនុវត្ត ក្រសួងរៀបចំដែនដី នគរូបនិយកម្ម និងសំណង់

អាស័យដ្ឋានៈ មហាវិថីព្រះមុនីវង្ស

ទំនាក់ទំនងៈ លោក ទី យ៉ាវ រដ្ឋលេខាធិការ

ទូរស័ព្ទៈ ៨៥៥-០២៣ ២១៥ ៦៥៩ និង ៨៥៥-០២៣ ២១៥ ៦៦០

ទូរសារៈ ៨៥៥-០២៣ ២១៥២៧៧

អ៊ីម៉េលៈ mlmupc@bigpond.kh

ផ្នែកបរិស្ថាន ព ( ការវាយតំលៃមួយភាគ)

កាលបរិច្ឆេតរៀបចំ ភីឌ ថ្ងៃទី ២០ កញ្ញា ២០០១

កាលបរិច្ឆេតវាយតំលៃគំរោង ថ្ងៃទី ១៧ តុលា ២០០១

កាលបរិច្ឆេតប្រជុំក្រុមប្រឹក្សាគំរោង ថ្ងៃទី ២ មេសា ២០០១

១. ជីវប្រវត្តិប្រទេស និងតំបន់ បរិបទប្រវត្តិសាស្ត្រៈ

ប្រជាជនកម្ពុជាបានទទួលរងការឈឺចាប់ពីប្រវត្តិសាស្ត្រច្របូកច្របល់ថ្មីៗ ដែលនៅក្នុងអំឡុងពេល នោះ ច្បាប់គ្រប់គ្រងសិទ្ធិកាន់កាប់ដីធ្លី មានភាពប្រែប្រួលឥតឈប់ឈរ ។ ក្នុងអំឡុងសម័យកាលមុនអាណានិគម មហាក្សត្របានធ្វើជាម្ចាស់លើដីធ្លីទាំងអស់ ក៏ប៉ុន្តែ ក្រុមគ្រួសារទាំងអស់មានសេរីភាពក្នុង ការធ្វើកសិកម្មលើផ្ទៃដីទំហំប៉ុនណាក៏បានអោយតែគេចង់ធ្វើ ។

ពួកអាណានិគមនិយមបារាំង ( ១៨៦៤-១៩៥៣) បានណែនាំនូវប្រព័ន្ធសិទ្ធិកាន់កាប់ លើអចលនទ្រព្យឯកជនផ្លូវការ ក៏ប៉ុន្តែប្រព័ន្ធនោះអាចប្រើប្រាស់ បានតែចំពោះតំបន់ដាំដុះស្រូវដែលមានប្រជាជនច្រើន ជាងគេប៉ុណ្ណោះ ។ រដ្ឋាភិបាលកម្ពុជាឯករាជ្យ បានរក្សាទុកនូវប្រព័ន្ធច្បាប់របស់បារាំងនោះ ក៏ប៉ុន្តែ ការរីកចំរើនក្នុងការចុះបញ្ជីជាផ្លូវការអំពីសិទ្ធិកាន់កាប អចលនទ្រព្យនៅមានកំរិតនៅឡើយ ។ ខ្មែរក្រហមដែលបានឡើងកាន់អំណាចនៅក្នុងឆ្នាំ ១៩៧៥ បានរឹបអូសយកដីធ្លីទាំងអស់ ហើយនិងបានបំផ្លាញនូវឯកសារដីធ្លីទាំងអស់ ដោយរាប់បញ្ចូលទាំងប័ណ្ណសំគាល់កម្មសិទ្ធិ និងផែនទីសុរិយោដី ។ បន្ថែមពីលើនេះ របបដែលបានសំលាប់ប្រជាជនអស់ប្រមាណជា ២លាននាក់នេះ បានធ្វើអោយមានការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ។

ពួកគេបានបង្ខំ ប្រជាជនរាប់សែននាក់អោយផ្លាស់ទីលំនៅពីទីក្រុងនានាទៅទីប្រជុំជន ទៅជនបទ ហើយនិងពីតំបន់មួយទៀត ។

មាន ប្រជាជនជាច្រើនពាន់នាក់ក៏បានរត់គេច ខ្លួនឆ្លងព្រំដែនដែរ ។ សិទ្ធិធ្វើជាម្ចាស់លើដីធ្លី ត្រូវបានបង្កើតអោយមានឡើង វិញនៅក្នុងឆ្នាំ១៩៨៩

ដោយអនុញ្ញាតិអោយកសិករនានាប្រកាសនូវសិទ្ធិកាន់កាប់ដីឡូតិ៍រហូតដល់ប្រាំហិចតា បន្ទាប់ពីអ្នក ទាំងនោះបានធ្វើកសិកម្មលើដីទាំងនោះអស់រយៈពេល៥ឆ្នាំជាប់ៗគ្នា ហើយក្រុមគ្រួសារនានាអាចទទួលបាននូវប័ណ្ណ សំគាល់កម្មសិទ្ធិដីឡូតិ៍សំរាប់តាំងទីលំនៅរហូតដល់២.០០០ម៉ែត្រការ៉េ ។ សិទ្ធិសម្បទានត្រូវបានផ្តល់អោយសំរាប់ដីឡូតិ៍ ដាំដំណាំលើសពី៥ហិចតា ។ ដីដែលទុកចោលទំនេរលើសពីបីឆ្នាំត្រូវក្លាយជាកម្មសិទ្ធិរបស់រដ្ឋ ។ តាមការអនុម័តលើច្បាប់ ដីធ្លី

ឆ្នាំ១៩៩២ មានកម្មវិធីមួយត្រូវបានគេផ្តួចផ្តើមគំនិតឡើង ដោយអំពាវនាវអោយមានការដាក់ពាក្យស្នើសុំប័ណ្ណកាន់ កាប់ដីធ្លី

ដើម្បីបញ្ជាក់បន្ថែមនូវសិទ្ធិប្រើប្រាស់ និងកាន់កាប់ ។ ពេលនោះ មានប្រជាជនដាក់ស្នើសុំច្រើនជាង ៤លាននាក់ ក៏ប៉ុន្តែ ត្រឹមពាក់កណ្តាលឆ្នាំ ២០០១ មានប្រជាជនតែ ១៥ភាគរយប៉ុណ្ណោះ ត្រូវបានគេផ្តល់អោយ ដោយសារតែ សមត្ថភាពរបស់រដ្ឋាភិបាលមានក៏រិត ។ ស្ថានភាពបច្ចុប្បន្ន និងបញ្ហានៅក្នុងផ្នែកសំខាន់ៗ: ស្ថិតិអំពីដីធ្លី និងកម្មសិទ្ធិ ហើយនិងការប្រើប្រាស់មានមិនគ្រប់គ្រាន់ទេនៅក្នុងប្រទេសកម្ពុជា ។ ពតិមានដែលគេអាច រកបានបង្ហាញអោយឃើញថា ប្រទេសកម្ពុជា (សំរាប់ឆ្នាំ១៩៩៨) មានទំហំដីប៉ាន់ស្មាន ១៨លានហិចតា (រាប់បញ្ចូល ទាំងទន្លេ និងបឹង) ដែលក្នុងនោះមានផ្ទៃដី ២,៧លានហិចតា សំរាប់ធ្វើកសិកម្ម និង ១លានហិចតាជាទីប្រជុំជន ហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវទឹក (តារាង ១) ។ តាម

របាយការណ៏ បានអោយដឹងថា តំបន់ការពារធម្មជាតិមានទំហំ ៣,៣ លានហិចតា

ចំណែកឯតំបន់សម្បទានព្រៃឈើមានផ្ទៃទំហំ ៨លានហិចតា និងតំបន់សម្បទាននេសាទមានផ្ទៃទំហំ ១លាន ហិចតា ។ ផ្ទៃដីដែលមានគ្រាប់មីនមានទំហំ ០,២លានហិចតាទៀត ។ មានផ្ទៃដីទំហំប្រហែល ១,៨លានហិចតា ត្រូវ គេស្មានថា មិនបានគិតបញ្ចូលដោយសារកង្វះខាតស្ថិតិ ។

តារាង ១: ប្រទេសកម្ពុជា-ការប៉ាន់ស្មានប្រភេទដី និងការប្រើប្រាស់ ឆ្នាំ ១៩៩៨

១) បំណែងចែកផ្ទៃដីនិមួយៗនៅលើខ្សែបន្ទាត់នេះ ត្រូវបានគេលើកយកគិតគូរ អំពីភាពខុសគ្នារវាងផលបូកសរុបនៃ ទំហំផ្ទៃដី ដែលគេបានចែកជាផ្នែក ឬតំបន់ និងផ្ទៃដីសរុបទាំងអស់គិតជាហិចតា ។ ប្រភព: ដកស្រង់ចេញពី សៀវភៅ របស់ Kato និង៏ លលិាមស (ឆ្នាំ១៩៩៩, ទំព័រ ២៥) ។ ប្រវត្តិនៃការគ្រប់គ្រងដីធ្លី និងរដ្ឋបាលនៅក្នុងប្រទេសកម្ពុជា វិលត្រលប់ទៅរកច្បាប់រដ្ឋប្បវេណីនៃឆ្នាំ ១៩២០ ដែលបានបង្កើតតាមប្រព័ន្ធច្បាប់ដីធ្លីរបស់បារាំង ក្នុងការទទួលស្គាល់

សិទ្ធិកាន់កាប់លើទ្រព្យឯកជន ។ តាមរបាយការណ៍បានអោយដឹងថា ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៦០ ពេលនោះមាន ប្រព័ន្ធច្បាប់គ្រប់គ្រងដីធ្លីគ្រប់គ្រាន់ រាប់បញ្ចូលទាំងការធានាអះអាងអំពីសិទ្ធិកាន់កាប់លើអចលនទ្រព្យឯកជន ជាមួយ និងឯកសារដីធ្លីដែលមានទាំងប័ណ្ណសំគាល់កម្មសិទ្ធិដី និងផែនទីសុរិយោដីទៀតផង ។ គេបាននិយាយថា ប្រព័ន្ធគ្រប់គ្រង ដីបានចាបផ្តើមមានការលំបាកឡើង១ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៧០-៧៥ ។ ក្រោយមក នៅក្រោមរបបប៉ុលពត (ឆ្នាំ១៩៧៥-៧៩) មិនត្រឹមតែសិទ្ធិកាន់កាប់លើទ្រព្យឯកជនត្រូវបានបំផ្លាញទាំងស្រុងនោះទេ សូម្បីតែឯកសារទាំងអស់ ក៏ត្រូវបានបំផ្លាញចោលដែរ រាប់បញ្ចូលទាំងប័ណ្ណសំគាល់កម្មសិទ្ធិ និងផែនទីសុរិយោដី ។ អ្នកដែលមានអាជីពខាងគ្រប់ គ្រងដីធ្លី និងតាក់តែងច្បាប់ ការចុះបញ្ជីនិងការស្ទាបស្ទង់ ក៏ត្រូវបានគេដាក់ពង្រាយសារជាថ្មី អោយទៅនៅជនបទ ចាកចេញពីប្រទេស ឬក៏ត្រូវបានគេសំលាប់ ។ របបក្រោយរបបប៉ុលពត (១៩៧៩-១៩៨៩) បានរៀបចំសហករណ៍ជា ច្រើន ធ្វើជាមូលដ្ឋាននៃការប្រកាសសិទ្ធិប្រើប្រាស់ដីកសិកម្មគឺៈ សិទ្ធិប្រើប្រាស់លំនៅដ្ឋាន ត្រូវបានបែងចែកដោយឈរ លើមូលដ្ឋាននៃការកាន់កាប់ នៅខណៈដែលកម្មសិទ្ធិដីនៅតែស្ថិតនៅក្នុងការគ្រប់គ្រងរបស់រដ្ឋ ។ នៅក្នុងឆ្នាំ ១៩៨៩ រដ្ឋាភិបាលបានណែនាំសាជាថ្មីនូវសិទ្ធិកាន់កាប់លើអចលនទ្រព្យឯកជន ក្នុងនោះកម្មសិទ្ធិដែលត្រូវចេញអោយសំរាប់ដី តាំងទីលំនៅឯកជនមានទំហំរហូតដល់ ២.០០០ ម៉ែត្រការ៉េ ។ សិទ្ធិកាន់កាប់ដីសំរាប់ធ្វើកសិកម្មតិចជាង ៥ហិចតា ហើយនិងសិទ្ធិសម្បទានសំរាប់ដីដាំដំណាំមានច្រើនជាង ៥ហិចតា ។ បច្ចុប្បន្ននេះ ការគ្រប់គ្រងសិទ្ធិលើអចលនទ្រព្យ បានរីករាលដាលយ៉ាងទូលំទូលាយដល់ទីភ្នាក់ងារជាច្រើនរបស់រដ្ឋាភិ បាល ។ ក្រសួងរៀបចំដែនដី នគរូបនិយកម្ម និងសំណង់ (ដែលត្រូវបានបង្កើតឡើងកាលពីឆ្នាំកន្លងទៅ) គឺជាទីភ្នាក់ងារ របស់រដ្ឋាភិបាល ដែលមានតួនាទីទទួលខុសត្រូវ ជាបឋមលើការគ្រប់គ្រងដីធ្លី ដោយរាប់បញ្ចូលទាំងគោលនយោបាយ និងការសំរបសំរួលលើការចុះបញ្ជី និងគ្រប់គ្រងដីធ្លី ផែនការប្រើប្រាស់ដី ការស្ទាបស្ទង់សុរិយោដី និងប្រថពីវិភាគ ការវាយតំលៃលើអចលនទ្រព្យ និងការគូរផែនទី ។ ការអនុវត្តជាក់ស្តែងនៃការចុះបញ្ជីដី ការគ្រប់គ្រងការលក់ដូរដី ការ ប្រមូលពន្ធដី (ពិបាកធ្វើបាន) ហើយនិងផែនការប្រើប្រាស់ដី ត្រូវបានអនុវត្តដោយការិយាល័យរបស់ក្រសួងរៀបចំដែន ដីនគរូបនិយកម្ម និងសំណង់ ដែលមាននៅតាមបណ្តាខេត្ត និងក្រុងនានា ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារៈទទួលខុសត្រូវចំពោះការគ្រប់គ្រងផ្ទៃដីដែលមានព្រៃឈើ និងតំបន់ដីសើម ។ នាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិ រដ្ឋរបស់ក្រសួងហិរញ្ញវត្ថុ មានភារៈទទួលខុសត្រូវក្នុងការគ្រប់គ្រងដី និងអចលនទ្រព្យរបស់រដ្ឋដទៃ១ទៀត ។ ដោយ សារតែសមត្ថភាពអន់ខ្សោយរបស់តុលាការ (ដែលបានបង្ហាញអោយឃើញ ច្បាស់នូវភាពមិនច្បាស់លាស់នានានៃច្បាប់ដី ធ្លីឆ្នាំ ១៩៩២) ក្នុងការដោះស្រាយរឿងក្តីដីធ្លីគណៈកម្មាការជាតិដោះស្រាយ រឿងជំលោះដីធ្លី (ដែលហៅកាត់ថា NLDSC) រួមជាមួយនិងគណៈកម្មាធិការនានាតាមខេត្ត ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ ១៩៩៩ ដើម្បីដោះស្រាយ ជំលោះដីធ្លីក្រៅតុលាការ ។ ការដោះមីន (ការយកគ្រាប់មិនទាន់ផ្ទុះចេញ) ចេញពីដី និងការបែងចែក ដីដែលបានដោះ មីនរួចហើយ គឺជាការទទួលខុសត្រូវរបស់ខេត្ត ។ ស្រដៀងគ្នាដែរ ការបែងចែកសម្បទានព្រៃឈើ និងនេសាទ ហាក់ ដូចជា ត្រូវទទួលរ៉ាប់រងដោយថ្នាក់ខេត្ត

រឺក៏ដោយអ្នកនយោបាយនានាគ្រប់លំដាប់ថ្នាក់ ។ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ ប័ណ្ណសំគាល់កម្មសិទ្ធិដីឯកជន ត្រូវបានចេញអោយ ជាពិសេសនៅទីក្រុងភ្នំពេញ ក៏ប៉ុន្តែ ចេញអោយបានត្រឹមតែប្រហែល ២៥%ប៉ុណ្ណោះ ។ ច្បាប់ដីធ្លីឆ្នាំ ១៩៩២ មិនអនុញ្ញាតិអោយមានកម្មសិទ្ធិដីនៅក្នុងតំបន់ ជនបទទេ គឺអនុញ្ញាតិអោយមានត្រឹមតែ សិទ្ធិកាន់កាប់ប៉ុណ្ណោះ ។ តាមការអនុម័តនៃច្បាប់ដីធ្លីឆ្នាំ ១៩៩២ មានកម្មវិធី មួយត្រូវបានផ្តួចផ្តើមឡើង ដោយអំពាវនាវអោយមានការដាក់ពាក្យសុំប័ណ្ណកាន់កាប់ដី ដើម្បីអះអាងបញ្ជាក់អំពីសិទ្ធិ ប្រើប្រាស់ សិទ្ធិតាំងទីលំនៅ ។ តាមប្រមើលទៅ មានប្រជាជនដាក់ពាក្យស្នើសុំច្រើនជាង ៤លាននាក់ ក៏ប៉ុន្តែ រដ្ឋមិន មានសមត្ថភាពដោះស្រាយនូវសំណើរ ទាំងអស់នោះទេ ហើយមានប្រជាជនតាមជនបទប្រហែលតែ ១៥ភាគរយប៉ុណ្ណោះ បានទទួលប័ណ្ណប្រើប្រាស់ដី ។ ចំពោះដីសាធារណៈវិញ តាមប្រមើលទៅ រដ្ឋមិនបានដឹងអំពីចំនួនទីតាំង និងព្រំដែនរបស់ ដីដែលស្ថិតនៅក្រោមការគ្រប់គ្រង របស់ខ្លួនទេ ។ ជាក់ស្តែង មានផ្ទៃដីជាច្រើនដែលគេមិនបានស្ទង់ មិនបានគូរផែនទី រឺមួយក៏មិនបានផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិ ។ យោងទៅតាមច្បាប់ដីធ្លីឆ្នាំ ១៩៩២ បានចែងថា ដីសាធារណៈចែកចេញ ជាពីរប្រភេទគឺមាន "ដីសាធារណៈរបស់រដ្ឋ" និង "ដីឯកជនរបស់រដ្ឋ" ដែលដីប្រភេទទីមួយ មិនអាចលក់រឺប្រើប្រាស់ ដើម្បីបង្កើតឡើងនូវសិទ្ធិដីឯកជនណាមួយទេ (ហើយគឺជាដី សំរាប់អភិរក្សតែប៉ុណ្ណោះ) ប៉ុន្តែ ប្រភេទដីទីពីរ អាចលក់បាន ហើយមានតែក្រសួងនានា និងទីភ្នាក់ងាររបស់រដ្ឋទេ ដែលមាន សិទ្ធិលក់ដីទាំងនោះបាន ហើយចំណូលដែលបានមក នោះមិនចាត់ចូលក្នុងផលប្រយោជន៍សាធារណៈសំរាប់បង្វិលចូលក្នុង រតនាគារទេ ។ តាមរបាយការណ៍បានអោយដឹងថា ក្រៅពីដីសាធារណៈ (ដែលសន្មត់ថា ជាដីសាធារណៈរបស់រដ្ឋ) នៅមានដីដែលមានព្រៃឈើចំនួន ៨លានហិចតា និង តំបន់ដីសើម ១លានហិចតាទៀត ដែលត្រូវបានគេចាត់ទុកថាជា ដីព្រៃ សម្បទាន និងនេសាទ ក៏ប៉ុន្តែ ដីសម្បទានទាំង  នេះមិនស្ថិតនៅក្រោមច្បាប់ណាមួយទេ ។ ហេតុដូច្នេះហើយ សូម្បីតែដីព្រៃឈើ ដែលច្បាប់បានចែងពិតប្រាកដថាជា "ដីសាធារណៈរបស់រដ្ឋ" ហើយក៏ដោយ ក៏ត្រូវបានប្រគល់ទៅអោយសម្បទាន ជនសំរាប់ធ្វើអាជីវកម្មដែរ ។ ទាំងរដ្ឋាភិបាល ទាំងអ្នកផ្តល់ជំនួយពិតជាដឹងច្បាស់ណាស់ថា បញ្ហាដែលសំខាន់ជាងគេ និងបញ្ហាធំធេងបំផុត ដែល នាំទៅរកភាពក្រីក្រ គឺកង្វះខាតសន្តិសុខកាន់កាប់ដីធ្លី (និងពាក់ព័ន្ធទៅនឹងភាពគ្មានដីធ្លី) ហើយនិងសិទ្ធិតឹងតែងក្នុងការ ប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួម ។ និមិត្តហេតុនៃបញ្ហានេះ ត្រូវគេមើលឃើញច្បាស់ថា ចំនួនប្រជាជនដែលគ្មានដីធ្លី កើនឡើង ដោយសារប្រជាជនទាំងនោះ ត្រូវគេធ្វើអោយមានការឈឺចាប់ រឺក៏បង្ខំអោយលក់ដី ហើយនិងចំនួនសុំណុំ រឿងជំលោះដីធ្លីយ៉ាងច្រើនកំពុងតែធ្វើអោយស្ទះដល់ស្ថាបន្យតុលាការ និងស្ថាបន្យដទៃៗទៀត ។ ការសិក្សាថ្មីៗនេះ បានបង្ហាញអោយឃើញនូវនិន្នាការដ៏សំខាន់មួយ និងដែលកំពុងកើនឡើងនៅក្នុងបញ្ហាគ្មានដីធ្លី (បានរកឃើញថា មាន ២០ភាគរយនៃចំនួនប្រជាជននៅតាមជនបទ តាមការស្ទាបស្ទង់ប៉ាន់គំរូមួយចំនួន) និងការរឹតត្បិតចំពោះសិទ្ធិប្រើប្រាស់

ធនធានទ្រព្យសម្បត្តិរួម (ព្រៃឈើ និងតំបន់ដីសើម) ដែលជាតំបន់ផ្តល់នូវប្រាក់ចំណូលប៉ាន់ស្មានចំនួន ២០ភាគរយ ដល់ក្រុមគ្រួសារនៅតាមជនបទមួយចំនួន ។ មានយោបល់ជាច្រើនលើកឡើងថា ភ្នាក់ងាររបស់រដ្ឋជាច្រើន ដូចជា យោធា និងអ្នកនយោបាយមួយចំនួនបានដកហូតយកដីរបស់ពួកគេ ដោយសំអាងថា ដីទាំងនោះគ្មានការទទួលស្គាល់ជាផ្លូវការ ។ នៅក្នុងករណីដែលធនធានធម្មជាតិដែលសក្តិសមសំរាប់ប្រើប្រាស់ក្នុងពាណិជ្ជកម្ម ដូចជា ដីមានព្រៃឈើ (សំរាប់លក់) រឺក៏ តំបន់ដីសើម (សំរាប់នេសាទ) មានរបាយការណ៍ជាច្រើនបានឱ្យដឹងថា សម្បទាននានាសំរាប់ការប្រើប្រាស់របស់ពួកគេ ជាញឹកញាប់ត្រូវបានផ្តល់ទៅអោយអ្នកវិនិយោគទុននានា ដោយតំលៃយ៉ាងទាប ។ មានការព្រួយបារម្ភថា ការបែងចែកដីដែលបានសំអាតហើយគឺមានលក្ខណៈមិនស្មើភាព និងមានលក្ខណៈពិសេស ហើយមានលក្ខណៈស្មុគ្រស្មាញ ដោយសារតែកង្វះខាតនៃសេវាកម្មផ្តល់ប័ណ្ណសំគាល់ដីធ្លី ក្នុងការធ្វើអោយអ្នកទទួលមានសិទ្ធិជាផ្លូវការ ។ ចាប់តាំងពីឆ្នាំ
១៩៩៨
មក ប្រទេសកម្ពុជា បានទទួលសន្តិភាព និងស្ថេរភាពជាលើកដំបូងក្នុងរយៈពេល៣០ឆ្នាំកន្លងទៅ ។ លទ្ធិប្រជាធិបតេយ្យកំពុងតែចាក់ឫស ហើយរដ្ឋាភិបាលបានសំរេចចិត្តរៀបចំការបោះឆ្នោតឃុំជាលើកដំបូង នៅក្នុងទូទាំងប្រទេស នៅខែកុម្ភៈ ឆ្នាំ
២០០២ និងមានការអធ្យាស្រ័យដល់ប្រជាពលរដ្ឋដែលបានរៀបចំការតវ៉ាប្រឆាំងនានា នៅក្នុងទីក្រុង ភ្នំពេញ និងនៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋាភិបាលដទៃៗទៀត ។ ស្ថានភាពសេដ្ឋកិច្ចមានការរីកលូតលាស់ឥតឈប់ឈរ ដែលមានអត្រាកំណើនប្រចាំឆ្នាំគិតជាមធ្យមប្រហែល ៥ភាគរយ ។ ប៉ុន្តែ ច្បាប់ដែលកំពុងគ្រប់គ្រងសិទ្ធិកាន់កាប់ដីធ្លី មិនច្បាស់លាស់ បានគំរាមកំហែងដល់ទាំងស្ថេរភាពនយោបាយ និងទាំងការអភិវឌ្ឍសេដ្ឋកិច្ច ។ ជំលោះបញ្ហាដីធ្លីកំពុងកើនឡើងពាក់ព័ន្ធទៅនឹងមនុស្ស ឬអង្គភាពនានាដែលមកពីខាងក្រៅសហគម ដើម្បីស្វែងរកដីសំរាប់ធ្វើពាណិជ្ជកម្ម ។ ប្រជាជន
ក្រីក្រ និងប្រជាជនដែលទទួលបានការអប់រំតិច បានចាញ់នៅក្នុងរឿងក្តី ពីព្រោះពួកគេមិនមានលទ្ធភាព ប្រើប្រាស់លុយ រឺអំណាចដែលជាកត្តាចាំបាច់ក្នុងការការពារសិទ្ធិរបស់ពួកគេ ។ ជាលទ្ធផល ដីទាំងនោះបានធ្លាក់ទៅក្នុង ដៃរបស់មនុស្ស រឺ អង្គភាពនានា ដែលជាប់ទាក់ទិនខាងនយោបាយ រឺក៏ពួកគេអាចទិញដីនោះដោយបង់ប្រាក់ក្រៅផ្លូវការ ជាពិសេស នៅតំបន់ទាំងឡាយណាដែលមានសក្តានុពលសំរាប់វិស័យទេសចរណ៍ ជួញដូរឈើ ឧស្សាហកម្ម រឺក៏ការ អភិវឌ្ឍន៍ទីក្រុង ។ ជំលោះលើបញ្ហាដីធ្លីនៅក្នុងប្រទេសកម្ពុជា មានកំរិតខ្ពស់ដោយមានមូលហេតុជាច្រើន ។ មូលហេតុសំខាន់មួយ នៅក្នុងចំណោមមូលហេតុទាំងឡាយគឺភាពមិនច្បាស់លាស់អំពីទីតាំងព្រំដែនដី ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អង្គភាពរដ្ឋផ្សេងៗ រឺក៏បុគ្គលឯកជន ។ នេះគឺជាលទ្ធផលនៃគោលនយោបាយ និងបទបញ្ញត្តមិនច្បាស់លាស់ ថាតើគួរចាត់ចំណាត់ថ្នាក់អំពីដីធ្លីទាំងនោះដោយរបៀបណា ហើយនិងកង្វះខាតផែនទីដែលមានគុណភាពខ្ពស់ដែលអាចកំណត់ព្រំដែនទាំងនោះបានជាក់លាក់ ។ បញ្ហានេះ វាឈានទៅដល់មានការប្រកាសទាមទារប្រជែងគ្នា ដើម្បីយកដីមួយកន្លែងដែលមានទីតាំងស្ថិតនៅកន្លែងតែមួយ ។ នៅក្នុងករណីខ្លះ ការទាមទារទាំងនោះគឺកើតមានឡើងរវាងក្រសួងផ្សេងៗគ្នារបស់រដ្ឋា

ភិបាល ។ នៅក្នុងករណីខ្លះទៀត គឺកើតមានឡើងរវាងកសិករដែលបានតាំងទីលំនៅ នៅលើដីនោះជាមួយនិងទីភ្នាក់ងាររបស់រដ្ឋាភិបាលនានាដែលបែងចែកដីនោះថា ជាដីសម្បទានសំរាប់បំរើអោយផលប្រយោជន៍ពាណិជ្ជកម្ម ។ នៅមានករណី

ខ្លះទៀត គឺកើតមានជំលោះរវាងបុគ្គលឯកជននានា ។ មូលហេតុទីពីរ គឺកង្វះខាតសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការដោះស្រាយជំលោះនានា ទាំងតាមរយៈតុលាការ ឬតាមរយៈគណកម្មាការដោះស្រាយជំលោះដែលត្រូវបានបង្កើតឡើងកាលពីឆ្នាំ ១៩៩៩ សំរាប់ដោះស្រាយជំលោះដីធ្លីក្រៅតុលាការ ។ បញ្ហានេះ បានធ្វើអោយសុំណុំរឿងក្តីនៅកកស្ទះកើនឡើងកាន់តែច្រើន ដែលតាមទំលាប់ជំលោះរឿងដីនិមួយៗត្រូវការរយៈពេលបីបួនឆ្នាំក្នុងការដោះស្រាយ ។ លើសពីនេះ

ទៅទៀត ប្រជាជនដែលជាប់ពាក់ព័ន្ធនឹងការដោះស្រាយជំលោះ ច្រើនតែមិនយល់ច្បាស់អំពីច្បាប់ទាក់ទង រឺក៏និតិវិធីដែល

ពាក់ព័ន្ធ ហើយនិងបញ្ហាគ្រប់គ្រងដែលមិនច្បាស់លាស់ ហើយមិនត្រឹមត្រូវតាមច្បាប់ ។ បញ្ហានានា ត្រូវបានធ្វើអោយកាន់តែធ្ងន់ធ្ងរឡើង តាមរយៈកង្វះខាតតម្លាភាពទាំងនៅក្នុងដំណើរការ និងទាំងមូលហេតុនៃការសំរេចចិត្ត ។ បញ្ហានានាជាមួយនិងយន្តការដោះស្រាយជំលោះ កំពុងតែធ្វើអោយអន្តរាយដល់សេចក្តីទុកចិត្តរបស់ប្រជាជនសាមញ្ញនៅក្នុងប្រព័ន្ធផ្លូវការ ដែលគេមើលឃើញថា ជាការគាំទ្រដល់ពួកអ្នកមានប្រាក់ និងអ្នកមានអំណាច ។ គេមិនអាចកាត់បន្ថយជំលោះរឿងដីធ្លីដោយគ្មានពត៌មានល្អប្រសើរស្តីអំពីការប្រើប្រាស់ដីនោះទេ ដោយគ្មានបទបញ្ជានិងគោលនយោបាយច្បាស់លាស់ ដោយគ្មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដោះស្រាយជំលោះ ហើយដែលជាគោលការណ៍សំខាន់ គឺគេទាំងអស់គ្នាទទួលស្គាល់ជាទូទៅនូវការកំណត់ព្រំដែនទាំងនោះ ។ កង្វះខាតប័ណ្ណសំគាល់កម្មសិទ្ធិច្បាស់លាស់ វាក៏ធ្វើអោយប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាដែរ ដោយការធ្វើអោយបាត់បង់នូវការលើកទឹកចិត្តចំពោះការវិនិយោគ ។ ផលិតភាពសំរាប់ធ្វើស្រែចំការនៅក្នុងប្រទេសកម្ពុជា គឺ

មានកំរិតទាបជាងគេបំផុតនៅក្នុងតំបន់ អាស៊ីអគ្នេយ៍ទាំងអស់ ដែលទិន្នផលស្រូវផលិតបានជាមធ្យម បានត្រឹមតែ ១,៨តោនក្នុងមួយហិចតា បើប្រៀបធៀបទៅនឹងប្រទេសវៀតណាមគេផលិតបានទិន្នផលស្រូវជាមធ្យម ៣,៩តោនក្នុង១ហិចតា និងប្រទេសឡាវគេផលិតបានជាមធ្យម ២,៧តោនក្នុង១ហិចតា ដែលប្រទេសទាំងនេះមានអាកាសធាតុនិងអំណោយផលធនធានធម្មជាតិប្រហាក់ប្រហែលនឹងប្រទេសកម្ពុជាដែរ ។ ទិន្នផលស្រូវនៅក្នុងប្រទេសកម្ពុជាគឺគ្រប់គ្រាន់សំរាប់តែចិញ្ចឹមគ្រួសារទំហំមធ្យមបានតែរយៈពេល ៧ខែទេក្នុងមួយឆ្នាំ ។ ទិន្នផលដែលបានមកទាបនេះ ដោយសារតែជាចំបងគឺការវិនិយោគទុនលើផ្នែកបច្ចេកវិទ្យាគ្រប់គ្រងទឹកនៅមានកំរិតទាប ដែលជាកត្តាសំខាន់នាំមកនូវទិន្នផលស្រូវខ្ពស់ ។ ការធ្វើកសិកម្មស្រូវប្រហែល ៨៥ភាគរយ ពឹងផ្អែកលើទឹកភ្លៀង ហើយជាទូទៅប្រជាជនធ្វើស្រែតែម្តងទេក្នុងមួយឆ្នាំ ។ ការវិនិយោគទុនលើវិស័យកសិកម្មមានកំរិតទាប គឺជាមូលហេតុបណ្តាលមកពីកង្វះខាតសន្តិសុខលើសិទ្ធិកាន់កាប់ដីធ្លី ។ ការបង្កើនផលិតភាពកសិកម្មនឹងមានឥទ្ធិពលដ៏សំខាន់មួយ លើកំណើនសេដ្ឋកិច្ច និងភាពក្រីក្រ នៅ

ក្នុងប្រទេសកម្ពុជា ។ កសិកម្មគឺជាផ្នែកសេដ្ឋកិច្ចដែលសំខាន់ជាងគេបំផុតនៅក្នុងប្រទេសកម្ពុជា ដែលមាន ៤០ភាគរយ នៃ GDP និងប្រើប្រាស់កំលាំងពលកម្ម ៧០ភាគរយ ។ ភាពមិនច្បាស់លាស់អំពីសិទ្ធិដីធ្លី ក៏ជាកត្តាមួយធ្វើអោយរាំងស្ទះដល់ផ្នែកវិនិយោគក្នុងក្រុង និងឧស្សាហកម្ម ។ កង្វះ ខាតនៃច្បាប់ដីធ្លី គឺជាបញ្ហាមួយយ៉ាងសំខាន់សំរាប់វិនិយោគិនបរទេសនៅក្នុងប្រទេសកម្ពុជា( បញ្ហាដទៃៗទៀត មានដូច ជា ថ្លៃទឹក ថ្លៃភ្លើងមានតំលៃខ្ពស់ ហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ ហើយនិងការិយាល័យធិបតេយ្យច្រើនហួសហេតុ) ។ ទីបំផុត កង្វះខាតសិទ្ធិកាន់កាប់ដីធ្លីច្បាស់លាស់ បានឈានទៅដល់ ការបំផ្លាញរាលដាលដល់ធនធានធម្មជាតិ ។ នៅតាម តំបន់ជាច្រើន ដូចជាតំបន់ព្រៃឈើ តំបន់នេសាទ គឺគ្មាននរណាត្រួតត្រាទេ ហើយតំបន់ទាំងនោះ កំពុងត្រូវបាន គេធ្វើអាជីវកម្មដើម្បីរកប្រាក់ចំណេញសំរាប់រយៈពេលខ្លី ។ អង្គភាពដែលបានទទួលសម្បទានផ្នែកនេសាទ និងព្រៃឈើ គ្មានការធានាគ្រប់គ្រាន់ ក្នុងការគ្រប់គ្រងតំបន់ទាំងនោះប្រកបដោយចិរភាព សំរាប់ផលចំណេញរយៈពេលវែងនៅក្នុង ប្រទេសកម្ពុជាទេ ។ ប្រជាជនកំពុងតាំងទីលំនៅនៅតាមតំបន់ក្បែរឆ្នេរ និងតំបន់ដទៃៗទៀត ងាយនឹងធ្វើអោយមាន គ្រោះមហន្តរាយធម្មជាតិ ។ ផ្ទៃដីប្រហែល ៨០% ត្រូវបានគេប៉ាន់ស្មានថា វាស្ថិតនៅក្រោមការត្រួតត្រារបស់រដ្ឋ ទោះបី តំបន់នេះមានទំនាក់ទំនងតិចតួចទៅនឹងការប្រើប្រាស់ដីដែលមាន ឬភស្តុតាងសមរម្យសំរាប់ការប្រើប្រាសដីជាក់លាក់ក៏ ដោយ ។ ផ្ទៃដីព្រៃដែលត្រៀមបំរុងទុកជាច្រើន ជាក់ស្តែង ត្រូវបានបែងចែកជាដីកសិកម្ម ។ មានភាពចាំបាច់ក្នុងការកាត់ បន្ថយចំនួនដីដែលស្ថិតនៅក្រោមការត្រួតត្រារបស់រដ្ឋ ព្រោះថា បញ្ហានេះវាទាក់ទងទៅនឹងការប្រឹងប្រែងដែលមាន ប្រសិទ្ធិភាពជាងច្រើនដើម្បីការពារតំបន់សំខាន់ៗ ។ ពត៌មានដែលល្អប្រសើរស្តីអំពីថាតើ បច្ចុប្បន្ននេះ នរណាជាអ្នកប្រើ ប្រាស់ដីនោះ ហើយប្រើប្រាស់ដោយរបៀបណា និងការកំណត់ព្រំដែនច្បាស់លាស់ ព្រមទាំងការចែកចាយប័ណ្ណសំគាល់ កម្មសិទ្ធិនានា នឹងធ្វើអោយរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់មានលទ្ធភាពអាចគ្រប់គ្រងដីធ្លីបានល្អប្រសើរជាងនេះ ។

យុទ្ធសាស្ត្ររបស់រដ្ឋាភិបាល រដ្ឋាភិបាលបានទទួលស្គាល់សេចក្តីត្រូវការចំពោះបញ្ហាដីធ្លីចាប់តាំងពីចុងឆ្នាំ ១៩៨៩មកម្លេះ ។ រដ្ឋាភិបាលបានអនុម័ត ច្បាប់ដីធ្លីឆ្នាំ ១៩៩២ និងស្នើសុំអោយប្រទេសផ្តល់ជំនួយគាំទ្រផ្តល់ នូវប័ណ្ណសំគាល់កម្មសិទ្ធិដីនៅឆ្នាំ ១៩៩៥ ។ នៅក្នុងឆ្នាំ ១៩៩៩ ដោយការធ្វើសេចក្តីសំរេចចិត្ត ត្រូវបានកែលំអរដ្ឋាភិបាលបានប្រញាប់ប្រញាល់ដោះស្រាយបញ្ហា ដីធ្លីដោយៈ (i) បង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៅឆ្នាំ ១៩៩៩ (ii) ស្នើសុំនៅក្នុងអំឡុងពេលប្រជុំ CG នៅ ឆ្នាំ ២០០០ អោយអ្នកផ្តល់ជំនួយគាំទ្រក្នុងការដោះស្រាយបញ្ហាដីធ្លី (iii) បង្កើតក្រុមប្រឹក្សានយោបាយដីមួយនៅក្នុងឆ្នាំ ២០០០ ដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ធ្វើជាប្រធាន និងមានមន្ត្រីជាន់ខ្ពស់ជាច្រើនចូលរួមមកពី ក្រសួង និងស្ថាប័នចំនួន ១៧ រាប់បញ្ចូលទាំងក្រសួងបរិស្ថាន ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍ ជនបទ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការពារជាតិ (iv) អោយក្រុមប្រឹក្សារដ្ឋមន្ត្រីអនុម័ត "ឯកសាររាយការណ៍ស្តីអំពីគោលនយោបាយដីធ្លី" នៅក្នុងខែឧសភា ឆ្នាំ ២០០១ ដែលគូសបញ្ជាក់អំពីទិសដៅនៃគោល

នយោបាយរបស់រដ្ឋាភិបាលនៅក្នុងផ្នែកដីធ្លី ។ អត្ថបទ "ឯកសាររាយការស្តីអំពីគោលនយោបាយដីធ្លី" ត្រូវបានគេរាប់បញ្ចូលទៅក្នុងឯកសារភ្ជាប់លេខ៉ី ឧបសម្ព័ន្ធ២ និង១ច អោយរដ្ឋសភាជាតិ និងព្រឹទ្ធសភាអនុម័តពង្រៀងច្បាប់ដីធ្លី ថ្មីមួយដែលពង្រៀងនោះត្រូវបានឡាយព្រះហស្ថលេខាដោយព្រះមហាក្សត្រនៅថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០១ ។ យុទ្ធសាស្ត្ររបស់រដ្ឋាភិបាលដែលបានបង្ហាញនៅក្នុង "ឯកសាររាយការណ៍ស្តីអំពីនយោបាយដីធ្លី" បង្ហាញអោយគេឃើញច្បាស់អំពីគោលនយោបាយស្តីពីការគ្រប់គ្រងដីធ្លីរបស់រដ្ឋាភិបាល រដ្ឋបាលនិងការបែងចែក ។ រដ្ឋាភិបាលទាមទារអោយបង្កើនសន្តិធិដីរបស់រដ្ឋ និងប្រព័ន្ធបែងចែកប្រភេទដី បង្កើនសមត្ថភាពក្នុងការដោះស្រាយជំលោះនានា ចុះបញ្ជីដីទាំងអស់នៅក្នុងប្រទេស( ទាំងដីឯកជន និងដីសាធារណៈ) ដែលមានការប្រើប្រាស់រយៈពេលវែង ទាំងតាមនិតិវិធីបែបប្រពន្ធិកនិងមិនទាក់ទង ពង្រឹងសន្តិសុខកាន់កាប់ដីនិងការពារ រឺដោះស្រាយជំលោះដីធ្លីអោយបានឆាប់រហ័ស អភិវឌ្ឍផែនការប្រើប្រាស់ដីសំរាប់តំបន់អាទិភាព( រាប់បញ្ចូលទាំងតំបន់ដែលមានសក្តានុពលផ្នែកទេសចរណ៍ វិនិយោគផ្នែកឧស្សាហកម្ម តំបន់ទីក្រុង និងច្រកផ្លូវសំខាន់ៗ) កែលំអការគ្រប់គ្រងធនធានធម្មជាតិ និងអភិវឌ្ឍនិតិវិធីសំរាប់ការគ្រប់គ្រងដីធ្លីក្នុងទីក្រុង ។ រដ្ឋាភិបាលទទួលស្គាល់ថា ការអនុវត្តយុទ្ធសាស្ត្រនេះ នឹងជាដំណើរការរយៈពេលវែងមួយដែលទាមទារនូវការពិគ្រោះយោបល់ជាសាធារណៈដ៏ទូលំទូលាយ និងការបង្កើតអោយមានការស្រុះស្រួលមតិគ្នា ។ រដ្ឋាភិបាល ក៏នឹងត្រូវទាម ទារផងដែរនូវតួនាទីច្បាស់លាស់របស់ទីភ្នាក់ងារនានារបស់រដ្ឋាភិបាលដែលមានការជាប់ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងដី ។ អភិវឌ្ឍយន្តការសំរាប់កែលំអការសំរបសំរួលក្នុងចំណោមភ្នាក់ងារទាំងនោះ ។ រដ្ឋាភិបាលក៏នឹងចូលរួមផងដែរនៅក្នុងការបង្កើតបណ្តាញប្រថពីវិភាគដែលត្រឹមត្រូវ  ផែនទី  និងប្រព័ន្ធពតិមានអំពីដីធ្លី ។ រដ្ឋាភិបាលមើលឃើញគំរោងស្នើសុំថា ជាឧបករណ៍សំខាន់មួយ ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយទាំងនេះ ។ ប៉ុន្តែ នៅក្នុងប្រព័ន្ធអភិបាលកិច្ចខ្សោយ ការអនុវត្តជាក់ស្តែងនៃគោលនយោបាយទាំងនេះ នឹងពឹងផ្អែកយ៉ាងធ្ងន់ទៅលើការសន្យា
ផ្តល់អោយ និងសមត្ថភាពរបស់រដ្ឋាភិបាលដើម្បីអនុវត្តតំបន់កែទំរង់ទាំងនេះ ។

## ២.គោលដៅ

គោលបំណងទាំងអស់របស់គំរោងដែលដាក់ស្នើគឺដើម្បីកាត់បន្ថយភាពក្រីក្រ បង្កើនការអភិវឌ្ឍសេដ្ឋកិច្ច ជំរុញអោយមានស្ថេរភាពសង្គម និងកែលំអការគ្រប់គ្រងបរិស្ថាន ។ គោលដៅជាក់លាក់នៃគំរោងគឺដើម្បីកែលំអសន្តិសុខកាន់កាប់ដីធ្លី និងជំរុញការអភិវឌ្ឍទីផ្សារដីដែលមានប្រសិទ្ធិភាព ។ គោលដៅទាំងនេះ នឹងត្រូវសំរេចបានតាមរយៈ (ក) ការអភិវឌ្ឍគោលនយោបាយជាតិដែលជាក្របខ័ណ្ឌនិយតកម្ម និងស្ថាបន្សនានាសំរាប់គ្រប់គ្រងដី (ខ) ការផ្តល់អោយនិងចុះបញ្ជីសំគាល់កម្មសិទ្ធិនៅក្នុងទីក្រុង និងតំបន់ជនបទ និង(គ) ការបង្កើតប្រព័ន្ធគ្រប់គ្រងដីធ្លីដែលមានតម្លាភាពនិងមានប្រសិទ្ធិភាពមួយ ។ គំរោងស្នើសុំនោះគឺជាជំហានដំបូងក្នុងការគ្រប់គ្រង និងរដ្ឋបាលដីធ្លីរបស់រដ្ឋាភិបាល និងកម្មវិធីបែងចែកដែលហៅកាត់ថា ១ឡាំឱភច ដែលគេរំពឹងថានឹងត្រូវគេអនុវត្តសំរាប់រយៈពេល ១៥ឆ្នាំ ។ គោលដៅ

របស់កម្មវិធី LAMDP ដូចដែលបានបញ្ជាក់នៅក្នុងឯកសាររាយការណ៍ស្តីអំពីនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាលកម្ពុជា (ខែឧសភា ឆ្នាំ ២០០១) គឺត្រូវៈ (ក) ពង្រឹងសន្តិសុខកាន់កាប់ដីធ្លី និងទីផ្សារដី ហើយនិងការពារ រឺដោះស្រាយជំលោះដីធ្លី (ខ) គ្រប់គ្រង់ធនធានធម្មជាតិនិងដីប្រកបដោយលក្ខណៈមានប្រសិទ្ធិភាព ចិរភាព និងសមធម៌ និង(គ) ជំរុញការបែងចែកដីប្រកបដោយសមធម៌ ។

៣. សនិទានភាពចំពោះការពាក់ព័ន្ធរបស់ធនាគារ

ធនាគារពិភពលោកបានគាំទ្រគំរោងរដ្ឋបាល និងគ្រប់គ្រងដីធ្លីជាច្រើនទូទាំងពិភពលោក រាប់បញ្ចូលទាំងប្រទេសចំនួន៤នៅក្នុងតំបន់អាស៊ីអគ្នេយ៍ (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ហ្វីលីពិន ថៃ និងប្រទេសឥណ្ឌូនេស៊ី) ។ តាមរយៈគំរោងទាំងនេះ ធនាគារបានអភិវឌ្ឍជំនាញការជាច្រើនក្នុងការធ្វើសមាហរណកម្មគោលនយោបាយ ដែលជាទិដ្ឋភាពបច្ចេកទេសនិងស្ថាបន្យដែលទាមទារអោយកែលំអសន្តិសុខកាន់កាប់ដីធ្លី ។ IDA ក៏បានអភិវឌ្ឍផងដែរនូវទំនាក់ទំនងការងារល្អជាមួយរដ្ឋាភិបាល ដែលធ្វើអោយមានលទ្ធភាពអាចថែរក្សាទំនាក់ទំនងដែលត្រូវការចាំបាច់ក្នុងការដោះស្រាយបញ្ហាលំបាកនានាដែលកើតឡើងចៀសមិនរួចក្នុងពេលអនុវត្តគំរោងដី ។ ចុងបញ្ចប់ ធនាគារបានអភិវឌ្ឍទំនាក់ទំនងដែលមានប្រសិទ្ធិភាពជាមួយនិងអ្នកផ្តល់ជំនួយដទៃៗទៀតនៅក្នុងប្រទេសកម្ពុជា ដែលកំពុងធ្វើការទាំងលើបញ្ហាដីធ្លី និងបញ្ហានានាដែលទាក់ទងជិតស្និទ្ធិនៅនឹងដីធ្លី រាប់បញ្ចូលទាំងបរិស្ថាន ការកាត់បន្ថយភាពក្រីក្រ និងការតាំងទីលំនៅសាជាថ្មី ។ ធនាគារកំពុងតែកៀងគរជំនួយឧបត្ថម្ភសំរាប់គំរោងនេះ ហើយនិងកំពុងធ្វើការយ៉ាងជិតស្និទ្ធិជាមួយអ្នកផ្តល់ជំនួយ នៅក្នុងតំបន់ដែលទាក់ទងនានា ដើម្បីធានាថា កិច្ចខិតខំប្រឹងប្រែងត្រូវបានសំរបសំរួលបានយ៉ាងល្អ ។

៤. ការពិពណ៌នា

១-សមាសភាគំរោង
គំរោងរដ្ឋបាល និងការគ្រប់គ្រងដីរបស់ប្រទេសកម្ពុជា មានសមាសភាគដូចខាងក្រោមៈ
សមាសភាគ ១: ការអភិវឌ្ឍនយោបាយដីធ្លី និងក្របខ័ណ្ឌនិយតកម្ម (ក) ការអភិវឌ្ឍសមត្ថភាពនៃលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សានយោបាយដីធ្លី ។ (ខ) ការរៀបចំដាក់លាក់នៃគោលនយោបាយសំខាន់សំរាប់ការគ្រប់គ្រងនិងរដ្ឋបាលដីធ្លី ។(គ) ការអភិវឌ្ឍ និងការពង្រៀងលិខិតុបករណ៍ស្របច្បាប់ ។

សមាសភាគ ២: ការអភិវឌ្ឍស្ថាបន្យ

(ក) ការអភិវឌ្ឍស្ថាបន្យរយៈពេលវែងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គ្រប់លំដាប់ថ្នាក់ ។
(ខ) ការគ្រប់គ្រងគំរោង

(គ) ការអភិវឌ្ឍការគ្រប់គ្រងដីធ្លី និងកម្មវិធីអប់រំរដ្ឋបាល ។

(ឃ) ការអភិវឌ្ឍឧស្សាហកម្មស្ទាបស្ទង់របស់ឯកជន ។

សមាសភាគ ៣: កម្មវិធីផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិដី និងការអភិវឌ្ឍប្រព័ន្ធចុះបញ្ជីដី

(ក) ការចែកចាយពត៌មាន និងការចូលរួមពីសហគម ។

(ខ) កម្មវិធីផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិដីបែបប្រពាន្ធិក ។

(គ) កម្មវិធីផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិដីមិនទាក់ទង

(ឃ) ការអភិវឌ្ឍប្រព័ន្ធចុះបញ្ជីដីបែបទំនើប ។

សមាសភាគ ៤: ការពង្រឹងយន្តការសំរាប់ដោះស្រាយជំលោះ

(ក) សនិទានកម្មចំពោះយន្តការដំណោះស្រាយជំលោះដីធ្លីដែលមានស្រាប់ ។

(ខ) កសាងសមត្ថភាពនៅក្នុងស្ថាបន្យខេត្ត និងវិមជ្ឈការនៃការដោះស្រាយជំលោះនៅក្នុងខេត្តនានាដែលអនុវត្តគំរោង នេះ ។

(គ) បង្កើនសិទ្ធិឬឱកាសក្នុងការទទួលយកនូវសេវាកម្មដោះស្រាយជំលោះ និងការគាំទ្រខាងរដ្ឋបាលតាមរយៈជំនួយសមស្រប និងជំនួយដទៃទៀត សំរាប់ស្ថាបន្យដោះស្រាយជំលោះ ។

(ឃ) បង្កើនសិទ្ធិឬឱកាសក្នុងការផ្តល់នូវជំនួយឧបត្ថម្ភស្របច្បាប់ដល់ប្រជាជនដែលបានបាត់បង់ផលប្រយោជន៍នៅក្នុងជំលោះដីធ្លី ។

សមាសភាគ ៥: ការគ្រប់គ្រងដីធ្លី

(ក) ការបញ្ជាក់អំពីនិតិវិធីនានាសំរាប់កំណត់អោយបានច្បាស់លាស់នូវប្រភេទដីខុសៗគ្នា ដូចជា ដីមានព្រៃឈើ ដីតំបន់ការពារធម្មជាតិ ដីឯកជន ដីឯកជនសាធារណៈ និងតំបន់ស្រដៀងៗគ្នាផ្សេងៗទៀត ។

(ខ) ការផ្គត់ផ្គង់តាមសេចក្តីត្រូវការនូវរូបថត ថតពីលើអាកាស និងរូបភាពផ្តល់ឱ្យតាមផ្កាយរណប ។

(គ) ការរៀបចំផែនទីបែងចែកចំណាត់ថ្នាក់ដីសំរាប់ខេត្តនិមួយៗដែលស្ថិតក្នុងគំរោង ដោយការបង្ហាញអំពីព្រំដែនព្រៃ តំបន់ការពារធម្មជាតិ ដីដែលស្ថិនៅក្រោមការប្រើប្រាស់របស់ឯកជន ដីដែលស្ថិតនៅក្រោមការប្រើប្រាស់របស់សាធារណៈ ដីសម្បទាន និងដីស្រដៀងគ្នាដទៃៗផ្សេងទៀត ។

១. ការអភិវឌ្ឍគោលនយោបាយដី និងក្របខ័ណ្ឌនិយតកម្ម

២. ការអភិវឌ្ឍស្ថាបន្យ

៣. កម្មវិធីផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិដី និងការអភិវឌ្ឍប្រព័ន្ធចុះបញ្ជីដី ។

៤. ការពង្រឹងយន្តការសំរាប់ដោះស្រាយជំលោះ

៥. ការគ្រប់គ្រងដី

៥. ហិរញ្ញប្បទានសរុប ( គិតជាលានដុល្លាអាមេរិក)

រដ្ឋាភិបាលកម្ពុជា....................................៣

រដ្ឋាភិបាលអាល្លឺម៉ង់...........................៣.៥

រដ្ឋាភិបាលហ្វាំងឡង់..........................................៣.៥

IDA...................................................................២៣.៤

ថ្លៃដើមសរុបរបស់គំរោង............៣៣.៤

៦. ការអនុវត្ត

ថេរវេលាអនុវត្តគំរោង: គំរោងនេះនឹងកើតឡើងក្នុងរយៈពេល ៥ឆ្នាំ គឺឆ្នាំសារពើពន្ធ ២០០២ ដល់ ២០០៧ ។ គំរោងនេះនឹងត្រូវបញ្ចប់ត្រឹមខែ មិថុនា ឆ្នាំ ២០០៧ ហើយឥណទាន នឹងត្រូវបិទត្រឹមថ្ងៃទី ៣១ ខែវិច្ឆិកា ឆ្នាំ ២០០៧ ។

ការសំរបសំរួលគំរោង: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងទទួលខុសត្រូវចំពោះការអនុវត្ត គំរោងទាំងអស់ ។ ការិយាល័យគ្រប់គ្រងគំរោង ( ដែលហៅកាត់ថា "PMO" ) នឹងត្រូវបានបង្កើតឡើងនៅក្នុងក្រសួងនេះ ដើម្បីសំរបសំរួលសកម្មភាពគំរោង ។ ការិយាល័យគ្រប់គ្រងគំរោង នឹងត្រូវបានដឹកនាំដោយប្រធានគំរោងម្នាក់ដែលនឹងត្រូវរាយការណ៍ជូនក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ អំពីបញ្ហាផ្សេងៗក្នុងការអនុវត្តគំរោង និងរាយការណ៍ជូនក្រុមប្រឹក្សាគោលនយោបាយដី តាមរយៈអគ្គលេខាធិការសំរាប់ការណែនាំគោលនយោបាយ ។ ប្រធានគំរោងក៏នឹងធ្វើជាប្រធានគណកម្មាធិការបច្ចេកទេសគំរោងផងដែរ ដែលរួមមានអគ្គនាយកមកពីនាយកដ្ឋាននានាដែលកំពុងអនុវត្តគំរោង ។ ការិយ៉ាល័យគ្រប់គ្រងគំរោង នឹងទទួលខុសត្រូវចំពោះការធ្វើផែនការគំរោង ការសំរបសំរួល ការត្រួតពិនិត្យ គណនេយ្យ ការគ្រប់គ្រងហិរញ្ញប្បទាន និងការផ្គត់ផ្គង់ ។ គំរោងនេះ នឹងរួមមាន ៣ អនុផ្នែក គឺ: រដ្ឋបាលនិងហិរញ្ញវត្ថុ ការផ្គត់ផ្គង់ និងការធ្វើផែនការ-ការរៀបចំថវិការនិងការត្រួតពិនិត្យ ។ អនុផ្នែកនិមួយៗនឹងត្រូវបានដឹកនាំដោយប្រធានម្នាក់ដែលមានសមត្ថភាព និងបុគ្គលិកបច្ចេកទេសដែលមានសមត្ថភាព ។ នាយកដ្ឋានផ្សេងៗ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងអនុវត្តចំនុចនានារបស់គំរោង ។ ឧទាហរណ៍ លេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាគោលនយោបាយដី នឹងអនុវត្តសមាសភាគអភិវឌ្ឍន៍គោលនយោបាយ អគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ នឹងទទួលខុសត្រូវចំពោះការផលិតរូបថតដែលថតពីលើអាកាសនិងរូបថតត្រឹមត្រូវតាមស្តង់ដា អគ្គនាយកដ្ឋានគ្រប់គ្រងដីធ្លី នឹងអនុវត្តសមាសភាគគ្រប់គ្រងដី ហើយនិងអគ្គនាយកដ្ឋានសំណង់នឹងធ្វើផែន

ការនិងត្រួតពិនិត្យសំណង់ និងអាគាររបស់ក្រសួង និងជួសជុលសារជាថ្មី ហើយនិងសំណង់របស់ការិយាល័យស្រុក និងខេត្ត ។ ការិយាល័យគ្រប់គ្រងគំរោង នឹងត្រូវបានគាំទ្រដោយជំនួយបច្ចេកទេស ( ដែលនឹងត្រូវបានផ្តល់ហិរញ្ញប្បទានដោយរដ្ឋាភិបាលអាល្លឺម៉ង់ និងហ្វាំងឡង់) ។ ជាការបន្ថែមដល់ប្រធានក្រុមជំនួយបច្ចេកទេស ១ទៀត ដែលនឹងណែនាំប្រធានគំរោង នឹងមានទីប្រឹក្សាជំនួយបច្ចេកទេសនៅតាមតំបន់ចំនួន ៤នាក់ទៀត សំរាប់គាំទ្រដល់ក្រុមផ្សេងៗនៅក្នុងការិយាល័យគ្រប់គ្រងគំរោង ( ការផ្គត់ផ្គង់ហិរញ្ញវត្ថុ ការធ្វើផែនការនិងរៀបចំថវិកា និងត្រួតពិនិត្យ) ។ ក៏នឹងមានបុគ្គលិកផ្នែកជំនួយបច្ចេកទេសជាតិ និងអន្តរជាតិជាច្រើន នាក់ទៀតសំរាប់គាំទ្រដល់ក្រសួងនៅក្នុងការអនុវត្តគំរោងនេះ ។

ការត្រួតត្រាគំរោង: ក្រុមប្រឹក្សាគោលនយោបាយដី នឹងដើរតួជាគណកម្មាធិការនាយកសំរាប់គំរោងនេះ ។ ក្រុមប្រឹក្សានេះនឹង កោះប្រជុំយ៉ាងហោចណាស់ ៦ខែម្តង ដើម្បីត្រួតពិនិត្យមើលឡើងវិញនូវភាពរីកចំរើនដែលធ្វើបាន និងដើម្បីជួយដោះស្រាយបញ្ហានយោបាយណាមួយដែលកើតមានឡើង និងដែលអាចប៉ះពាល់ដល់ការអនុវត្តគំរោង ។

ទីភ្នាក់ងារប្រតិបត្តិ: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងប្រតិបត្តិគំរោងនេះ ។ ការិយាល័យតូចៗដែលគ្រប់គ្រងគំរោងតាមខេត្ត (រឺក្រុង) ដែលហៅកាត់ថា ១ភភីុច នឹងត្រូវបានគេបង្កើតឡើងនៅក្នុងខេត្តនិមួយៗទាំង ១០ និងទីក្រុងមួយ ( គឺរាជធានីភ្នំពេញ) ដែលជាកន្លែងចុះបញ្ជីបែបប្រពន្ធ័ក នឹងត្រូវបានគេធ្វើឡើង ។ ការិយាល័យគ្រប់គ្រងគំរោងរបស់ខេត្តទាំងអស់ នឹងគាំទ្រដល់ក្រុមចុះបញ្ជីដីធ្លី ។ នាយកនៃនាយកដ្ឋានគ្រប់គ្រងដីធ្លីខេត្តរឺក្រុង ក៏នឹងធ្វើជាប្រធានគំរោងខេត្តរឺក្រុងដែរ ហើយរាយការណ៏ជូនប្រធានគំរោងនៅឯការិយាល័យគ្រប់គ្រងគំរោងមជ្ឈឹម ស្តីអំពីបញ្ហាគំរោងទាំងអស់ ។ ប្រធានចុះជាប់តាមការដ្ឋានរបស់ក្រុមពិភាក្សាច្បាប់ប្រពន្ធ័ក នឹងរាយការណ៏ជូនប្រធានគំរោងខេត្ត ។ ការិយាល័យគ្រប់គ្រងគំរោងខេត្ត នឹងទទួលខុសត្រូវចំពោះ ( ក) ការសំរបសំរួល និងគ្រប់គ្រងសកម្មភាពគំរោងខេត្តក្រុង ( ខ) រៀបចំ និងបញ្ជូនរបាយការណ៏បច្ចេកទេស និងទៀងទាត់ពេលវេលា តាមតំរូវការទៅអោយប្រធានគំរោងត្រួតពិនិត្យ និង ( គ) ទំនាក់ទំនងជាមួយមន្ត្រីខេត្តក្រុងដទៃៗទៀត ។

៧. ភាពដែលអាចទ្រទ្រង់បាន

សកម្មភាពមួយចំនួននឹងត្រូវបានគេទទួលយកដើម្បីធានាអះអាងអំពីភាពដែលអាចទ្រទ្រង់គំរោងបាន ។ ទីមួយ: ដើម្បីធានាអះអាងថា អត្ថប្រយោជន៏នៃការផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិជាលើកដំបូងត្រូវបានទ្រទ្រង់រួច តាមរយៈការចុះបញ្ជីដោយមានការសំរុះសំរួលបន្តបន្ទាប់ ។ គំរោងនេះ នឹងរាប់បញ្ចូលទាំងយុទ្ធនាការផ្សព្វផ្សាយពតិមានសាធារណៈ ដើម្បីពន្យល់ពីភាពសំខាន់នៃការចុះបញ្ជីជាផ្លូវការ ដើម្បីថែរក្សាសន្តិសុខកាន់កាប់ដីធ្លី និងដើម្បីទទួលបាននូវជំនឿទុកចិត្ត ។ អង្គការក្រៅរដ្ឋាភិបាលដែលកំពុងធ្វើការនៅក្នុងភូមិនានា ក្នុងអំឡុងពេលពិភាក្សាច្បាប់បែបប្រពន្ធ័ក នឹងពង្រឹងដល់ពតិមាននេះ ។ ទីពីរ: គំរោងនេះ នឹងគាំទ្រដល់ការសិក្សាមួយ ដើម្បីអភិវឌ្ឍរចនាសម្ព័ន្ធ និងលំដាប់ដីដែលជា

កម្មសិទ្ធិដាច់ខាតសមស្រប ការគិតគូរអំពីផលប៉ះពាល់នៃការរៀបចំដី ដែលជាកម្មសិទ្ធិដាច់ខាត លើការសំរេចចិត្ត របស់ប្រជាជន ដើម្បីចុះបញ្ជីកិច្ចសំរុះសំរួលជាផ្លូវការ ។ ទីបី: គំរោងនេះ នឹងគាំទ្រការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស និងស្ថាបន្យដែលនឹងទ្រទ្រង់ការផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិ និងសកម្មភាពចុះបញ្ជី ក្រោយពីគំរោងនេះត្រូវបានបញ្ចប់ ។ ជាពិសេសការឧបត្ថម្ភរបស់គំរោងសំរាប់អភិវឌ្ឍប្រព័ន្ធចុះបញ្ជីដីធ្លីដែលមានប្រសិទ្ធិភាពមួយ នឹងជួយកសាងសមត្ថភាព ក្នុងការគ្រប់គ្រងការផ្ទេរប័ណ្ណសំគាល់កម្មសិទ្ធិដោយឈរលើមូលដ្ឋានដែលកំពុងកើតមានឡើង នៅពេលដែលអចលនទ្រព្យនានាត្រូវបានចុះបញ្ជីនៅក្នុងការិយាល័យដីធ្លី ។

៨. មេរៀនដែលបានសិក្សាពីប្រតិបត្តិការកន្លងទៅនៅក្នុងប្រទេស/តំបន់

រាប់បញ្ចូលទាំងការផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិដីដែលជាផ្នែកមួយនៃកម្មវិធីដ៏ទូលំទូលាយមួយ ។ បទពិសោធន៏ បង្ហាញថា គំរោងនានាបានផ្តោតការយកចិត្តទុកដាក់តិចតួចលើការផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិ មុនពេលគេបានឈានទៅដល់ការស្រុះស្រួលគ្នាមួយដែលមានលក្ខណៈជាតិស្តីអំពីគោលនយោបាយដីធ្លី ដែលកម្រនឹងទទួលបានជោគជ័យក្នុងការឆ្លើយតបទៅនឹងគោលដៅរបស់ពួកគេ ។ វិធីដោះស្រាយមួយដ៏ប្រសើរ គឺត្រូវបញ្ចូលការផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិដីដែលជាផ្នែកនៃគោលនយោបាយដែលមានលក្ខណៈទូលំទូលាយមួយ និងជាក្របខ័ណ្ឌស្ថាបន្យសំរាប់រដ្ឋបាល និងការគ្រប់គ្រងដីធ្លី ។ គំរោងដែលដាក់ស្នើសុំនោះ ត្រូវការការរបៀបដោះស្រាយដែលមានលក្ខណៈទូលំទូលាយដែលគាំទ្រដល់កំណែទំរង់និយតកម្ម និងនយោបាយ ការបង្កើតឡើងនូវការស្រុះស្រួលគ្នា និងការអភិវឌ្ឍស្ថាបន្យព្រមជាមួយ និងការផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិ ។ វាធ្វើអោយសកម្មភាព ទាំងនេះដំណើរការទៅជាបន្តបន្ទាប់ដោយប្រុងប្រយ័ត្ន ដើម្បីអោយការផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិបែបប្រពន្ធិក មិនអាចកើតមានឡើងចំពោះដីធ្លីទាំងឡាយដែលមានស្ថានភាពមិនច្បាស់លាស់ រហូតដល់ក្រោយស្ថានភាពនោះត្រូវវិគ្គាជាមួយនិងសមាជិកដែលចូលរួមពាក់ព័ន្ធ និងព្រំដែននានារវាងតំបន់ដែលត្រួតត្រាដោយរដ្ឋ និងឯកជនដែលគេបានក៏រិត ។ ការបង្កើតគំរោងតាមការសន្យាជាក់លាក់របស់រដ្ឋាភិបាល ។

មេរៀននៃគំរោងមុនៗគឺជាការសន្យាជាក់លាក់របស់រដ្ឋាភិបាល ដែលមានក៏រិតខ្ពស់បំផុតដែលតំរូវអោយបង្កើតនូវការស្រុះស្រួលគ្នា ស្តីអំពីបញ្ហាដែលពិបាកដោះស្រាយចំពោះ សិទ្ធិកាន់កាប់ដីធ្លី ។ នាយករដ្ឋមន្ត្រីប្រទេសកម្ពុជាបានគូសបញ្ជាក់ម្តងហើយម្តងទៀតថា សារៈសំខាន់នៃការធានា សិទ្ធិកាន់កាប់ដីដោយការផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិ និងការចុះបញ្ជីដីជាផ្លូវការ ។ សមាជិកដទៃៗទៀតរបស់រដ្ឋាភិបាល

រាប់បញ្ចូលទាំងសមាជិករបស់គណបក្សប្រឆាំងដែលនាំមុខគេ បានប្រកាសនូវការសន្យារបស់ពួកគេស្រដៀងគ្នា ដើម្បីធ្វើអោយសិទ្ធិកាន់កាប់ដីមានលក្ខណៈជាផ្លូវការ ។ ការបង្ហាញការសន្យានេះ ក្រុមប្រឹក្សារដ្ឋមន្ត្រីបានអនុម័តឯកសាររាយការណ៏មួយស្តីពីគោលនយោបាយដីធ្លី នៅក្នុងខែឧសភា ឆ្នាំ ២០០១ ហើយច្បាប់ដីធ្លីថ្មីត្រូវបានអនុម័តក្នុងខែសីហាឆ្នាំ ២០០១ ។ ការបង្កើតគំរោងផ្អែកលើបទពិសោធន៏នៃគំរោងសាកល្បង ។

ជាមួយនិងគំរោងផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិដីដែល ពិបាកដោះស្រាយពាក់ព័ន្ធនឹងនយោបាយ

គំរោងសាកល្បងមានសារៈសំខាន់យ៉ាងពិសេសដើម្បីរកអោយឃើញនូវបញ្ហា សក្តានុពល

និងដើម្បីអភិវឌ្ឍការរៀបចំព្រំដែនដោយពិភាក្សាតាមច្បាប់ដែលមានប្រសិទ្ធិភាពនិងសមរម្យ ។ គំរោង
ដែលដាក់ស្នើសុំនោះ ផ្អែកលើមូលដ្ឋាននៃមេរៀននានា ដែលបានសិក្សាពីគំរោងសាកល្បងជាច្រើនរបស់រដ្ឋាភិបាល
អាល្លឺម៉ង់ និងហ្វាំងឡង់ ក្នុងការផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិដីនៅក្នុងខេត្តទាំង ៥ ក្នុងប្រទេសកម្ពុជា រាប់បញ្ចូលទាំងសេចក្តី
ត្រូវការក្នុងការរៀបចំផែនការយ៉ាងហ្មត់ ចត់លើដំណើរចុះបញ្ជីបែបប្រពន្ធ័ក និងសេចក្តីត្រូវការក្នុងការផ្តល់អោយបាន
ឆាប់រហ័សនូវប័ណ្ណសំគាល់កម្មសិទ្ធិ បន្ទាប់ពីការបញ្ចប់ការពិភាក្សាច្បាប់ ក្នុងការធានាអះអាងថា កិច្ចព្រមព្រៀងដែល
បានសំរេចទាំងនោះ មិនខូចខាតទៅវិញទេ ។ ក្រុមដែលកំពុងអនុវត្តគំរោងសាកល្បងនានា ១អទណ និង ធិននមាផជ
នឹងបន្តគាំទ្រការអភិវឌ្ឍគោលនយោបាយស្ថាបន្យនានា និងនិតិវិធីផ្សេងៗបន្ថែមទៀត រហូតដល់គំរោងនេះមាន
ប្រសិទ្ធិភាព ដែលជាពេលដែលពួកគេនឹងក្លាយជាដៃគូពេញលេញជាមួយរដ្ឋាភិបាល និងី ឌា ក្នុងការគាំទ្រគំរោង នោះ ។
ការគូសបញ្ជាក់អំពីការចូលរួមរបស់សមាជិកដែលមានចំណែកក្នុងគំរោង ។ បទពិសោធន៏បង្ហាញអោយឃើញថា ការ
ចូលរួមដ៏សកម្មរបស់សមាជិកដែលមានចំណែកក្នុងគំរោងទាំងអស់គ្នា ក្នុងអំឡុងពេលរៀបចំគោលនយោបាយអោយ
បានជាក់លាក់ ការកំរិតព្រំដែនរវាងតំបន់ត្រួតត្រាដោយរដ្ឋនិងឯកជន និងការពិភាក្សាច្បាប់បែបប្រពន្ធ័កគឺមានលក្ខណៈ
សំខាន់ចំពោះភាពជោគជ័យរបស់កម្មវិធី ។ គំរោងដែលបានស្នើឡើង មានវិធានការណ៏នានាសំរាប់ការចូលរួមក្នុង
អំឡុងដំណើរនិមួយៗទាំងនេះ ។ ក្នុងអំឡុងពេលរៀបចំគោលនយោបាយអោយបានជាក់លាក់ គំរោងនេះនឹងគាំទ្រដល់
យុទ្ធនាការផ្សព្វផ្សាយពត៌មានជាសាធារណៈ តាមរយៈវិទ្យុ ទូរទស្សន៏ កាសែត និងតាមរយៈមធ្យោបាយសមស្រប
ដទៃៗទៀត ដើម្បីជំរាបដល់ប្រជាពលរដ្ឋអំពីខទាំងឡាយដែលមានចែងនៅក្នុងច្បាប់ដីធ្លីថ្មី ហើយនិងស្នើសុំអោយធ្វើ
អត្ថាធិប្បាយជាសាធារណៈស្តីអំពីពង្រៀងគោលនយោបាយដីធ្លី នៅពេលដែលពង្រៀងទាំងនោះត្រូវបានរៀបចំជាក់
លាក់ហើយ ។ ក្នុងអំឡុងពេលដំណើរបែងចែកប្រភេទដី និងកំរិតព្រំដែន គ្រប់សមាជិកដែលមានចំណែកនៅក្នុងគំរោង
ទាំងអស់នឹងចូលរួមនៅក្នុងដំណើរការពិគ្រោះយោបល់សាធារណៈមួយ ដើម្បីធានាអះអាងដល់កិច្ចព្រមព្រៀងដែលមាន
ការសំរេចចិត្តទូទៅ ។ ក្នុងអំឡុងពេលនៃការពិភាក្សាច្បាប់បែបប្រពន្ធ័ក អង្គការក្រៅរដ្ឋាភិបាលដែលមានឯកទេស
នឹងធ្វើការជិតស្និទ្ធិជាមួយអ្នកភូមិ ដោយពន្យល់អំពីដំណើរការនេះ ដោយការបង្កើតឡើងនូវឯកសារដីធ្លីសំរាប់ភូមិ
និងធានាអះអាងថា គ្រប់សមាជិកទាំងអស់របស់សហគមមានសិទ្ធិទទួលបាននូវប័ណ្ណសំគាល់កម្មសិទ្ធិដីដូចៗគ្នា ។
ការជំរុញអោយមានការចូលរួមពីផ្នែកឯកជន ។ គំរោងនានាដែលនៅកន្លែងដទៃបង្ហាញថា ការធ្វើអោយផ្នែកឯកជន
ពាក់ព័ន្ធទៅក្នុងការស្ទាបស្ទង់ និងភារកិច្ចបច្ចេកទេសដទៃៗទៀត អាចបង្កើនល្បឿននៃដំណើរផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិ
បានយ៉ាងច្រើន ។ ការប្រើប្រាស់អ្នកម៉ៅការឯកជនមានអត្ថប្រយោជន៏ជាច្រើន ។ អ្នកម៉ៅការទាំងនោះអាចត្រូវបានគេ
ជួលអោយបំពេញភារកិច្ចជាក់លាក់ ជាជាងជួលផ្នែករដ្ឋការ ហើយនិងអាចប្រើពួកគេបានតាមត្រូវការ ។ គេក៏អាច
ផ្តល់ការលើកទឹកចិត្តសំរាប់ការប្រតិបត្តិផងដែរ ( ដូចជា ថ្លៃចំណាយផ្អែកលើចំនួននៃកញ្ចប់ការងារដែលបានពិភាក្សា
ច្បាប់ហើយ) ដែលគេមិនអាចផ្តល់អោយបុគ្គលិករបស់រដ្ឋាភិបាលបាន ។ បច្ចុប្បន្ន ប្រទេសកម្ពុជាមានសមត្ថភាពផ្នែក
ឯកជនតិចតួចក្នុងការស្ទាបស្ទង់ និងធ្វើផែនទី ។ ដូច្នេះហើយ គំរោងនេះនឹងជួយបង្កើតអោយមានសមត្ថភាពផ្នែកឯកជន

ដោយការបណ្តុះបណ្តាលបុគ្គលឯកជននានា ព្រមជាមួយនិងបុគ្គលិកមកពីតាមក្រសួង ដើម្បីអោយពួកគេទាំងអស់គ្នាមានចំណេះដឹងដូចគ្នា ហើយបន្ទាប់មកប្រើទាំងក្រុមឯកជននិងទាំងក្រុមរបស់ក្រសួង សំរាប់ការពិភាក្សាច្បាប់បែបប្រពន្ធិក ។ គំរោងនេះ ក៏នឹងជំរុញអោយមានការអភិវឌ្ឍផ្នែកឯកជនដែរ តាមរយៈកម្មវិធីសិក្សាថ្នាក់សកលវិទ្យាល័យដែលសិក្សាអំពីការគ្រប់គ្រងនិងរដ្ឋបាលដី ។

៩. កម្មវិធីនៃអន្តរាគមន៍គោលដៅ (PTI) Y

១០. ទិដ្ឋភាពបរិស្ថាន (រាប់បញ្ចូលទាំងការពិគ្រោះយោបល់សាធារណៈ)

បញ្ហា: គំរោងនេះត្រូវបានគេចាត់ចូលក្នុងចំណាត់ថ្នាក់ប្រភេទ ព ពីព្រោះគេមិនរំពឹងថា មានផលប៉ះពាល់ដល់បរិស្ថានមិនល្អនោះទេ ។ ក្រៅពីការស្តារឡើងវិញ ឬការសាងសង់ទីកន្លែងការិយាល័យគំរោង និងអាគារដែលទាក់ទងផ្សេងៗទៀត គំរោងនេះនឹងគាំទ្រកិច្ចការរដ្ឋការ ការផ្លាស់ដី  ការទាញយកធនធានផលិតកម្មឧស្សាហកម្ម រឺក៏សកម្មភាពដទៃៗទៀតដែលមានសក្តានុពលបំផ្លាញដល់បរិស្ថាន ។ កិច្ចសន្យាសំរាប់ការងាររដ្ឋការនៅក្រោមគំរោងនេះនឹងត្រូវតែពិនិត្យអំពីផលប៉ះពាល់ដល់បរិស្ថាន ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ គ្រប់សកម្មភាពអភិវឌ្ឍស្ថាបន្យ និងគោលនយោបាយទាំងអស់ (គំរោងទាំងអស់នេះមានតំលៃប្រហែល ៥០ភាគរយ) គឺត្រូវបានគេវាយតំលៃចូលក្នុងបរិស្ថានប្រភេទ ជ ។ គំរោងទាំងនេះ
វាមិនតំរូវអោយមានការត្រួតពិនិត្យមើលឡើងវិញលើផ្នែកបរិស្ថានពិសេសទេ ។ក្នុងចំណោមគោលបំណងដទៃៗទៀត គំរោងនេះស្វែងរកការកែលំអការគ្រប់គ្រងធនធានធម្មជាតិ ដោយការគាំទ្រ ការអភិវឌ្ឍគោលនយោបាយ បទបញ្ជា និងនិតិវិធីនានាសំរាប់ចាត់ចំណាត់ថ្នាក់ប្រភេទដី ការបង្កើតពត៌មានដែល ចាំបាច់ក្នុងការចាត់ចំណាត់ថ្នាក់ដី (រាប់បញ្ចូលទាំងការផ្គត់ផ្គង់រូបថតដែលថតពីលើអាកាស និងរូបភាពដែលបានពីផ្កាយ រណប)
និងការបង្កើតផែនទីចាត់ចំណាត់ថ្នាក់ដី ដើម្បីបង្ហាញអំពីព្រំដែនដីដែលត្រូវបានកំណត់សំរាប់ការប្រើប្រាស់ ពិសេស និងស្ថិតនៅក្រោមការត្រួតត្រារបស់អង្គភាពផ្សេងៗរបស់រដ្ឋាភិបាល ។ ការឈានទៅដល់ការយល់ច្បាស់មួយ អំពីថាតើតំបន់ផ្សេងៗ នឹងត្រូវបានគេគ្រប់គ្រងដោយរបៀបណានៅពេលអនាគតនោះ គឺជាលក្ខ័ណ្ឌមុនដំបូងមួយសំរាប់ការធ្វើផែនការប្រើប្រាស់ដីដែលមានប្រសិទ្ធិភាព និងការគ្រប់គ្រងធនធានធម្មជាតិ ។ សកម្មភាពនេះក៏មានសារៈសំខាន់ផងដែរសំរាប់ការអនុវត្តដែលមានប្រសិទ្ធិភាព នូវច្បាប់ថ្មីស្តីអំពីការគ្រប់គ្រងព្រៃឈើ នេសាទ និងទឹក នៅក្នុងប្រទេសដែលបច្ចុប្បន្ននេះកំពុងត្រូវបានគេធ្វើពង្រៀង ដើម្បីដោះស្រាយជាមួយនិងប្រភេទនៃអចលនទ្រព្យរបស់រដ្ឋជាក់លាក់ ។ នៅក្នុងវិធីនេះ គេរំពឹងថា គំរោងនេះនឹងចូលរួមដោយផ្ទាល់ក្នុងការកែលំអការគ្រប់គ្រងបរិស្ថាននៅក្នុងប្រទេសកម្ពុជា ។ ដោយការបង្កើនវិនិយោគថ្មីនៅក្នុងវិស័យឧស្សាហកម្ម កសិកម្ម ការិយាល័យនិងផ្ទះនៅក្នុងក្រុង គំរោងនេះមានសក្តានុពលដោយប្រយោលប៉ះពាល់ដល់បរិស្ថានទាំងវិជ្ជមានទាំងអវិជ្ជមាន ។ លើផ្នែកវិជ្ជមាន ដោយការកែលំអការលើកទឹកចិត្តនានា ក្នុងការគ្រប់គ្រងធនធានទាំងនោះសំរាប់ផលប្រយោជន៍រយៈពេលវែង ។ គំរោងនេះអាចនឹងលើក

ទឹកចិត្តដល់កសិករទាំងឡាយអោយធ្វើវិនិយោគនៅក្នុងការអភិរក្សដី ហើយនិងលើកទឹកចិត្តដល់ក្រុមហ៊ុន និងសហគមនានាអោយគ្រប់គ្រងព្រៃឈើ និងតំបន់នេសាទប្រកបដោយចិរភាព ។ ដោយការធ្វើអោយសិទ្ធិកាន់កាប់ដីឡូតិ៍សំរាប់តាំងទីលំនៅក្លាយទៅជាផ្លូវការ គំរោងនេះជំរុញលើកទឹកចិត្តដល់ការវិនិយោគនៅក្នុងសកម្មភាពផ្សេងៗ និងហេដ្ឋារចនាសម្ព័ន្ធដែលកែលំអដល់លក្ខ័ណ្ឌបរិស្ថាន ដែលជាកន្លែងប្រជាជនរស់នៅនិងធ្វើការ ដូចជា ការគ្រប់គ្រងកាកសំណល់រឹង ប្រព័ន្ធផ្គត់ផ្គង់ទឹក និងសំភារៈអនាម័យ និងការធ្វើអោយសិទ្ធិកាន់កាប់ដីកសិកម្មភាពលក្ខណៈជាក់លាក់ ។ គំរោងនេះនឹងលើកទឹកចិត្តដល់ការវិនិយោគនៅក្នុងការគ្រប់គ្រងដីអោយបានត្រឹមត្រូវ ។ នៅលើផ្នែកអវិជ្ជមាន បើគ្មានការធ្វើផែនការប្រើប្រាស់ដី និងការប្រតិបត្តិអោយបានត្រឹមត្រូវទេ គំរោងនេះនឹងអាចបណ្តាលអោយមានការអភិវឌ្ឍទីក្រុងដែលមិនអាចត្រួតត្រាបាន ហើយបើគ្មានការបែងចែកចំណាត់ថ្នាក់ដីអោយបានសមរម្យទេ នោះអាចនឹងមានគ្រោះថ្នាក់នៃការផ្ទេរតំបន់រងទឹកភ្លៀងសំខាន់ៗ និងតំបន់ដែលមានបញ្ហាពិបាកដោះស្រាយផ្នែកបរិស្ថានដទៃៗទៀតអោយទៅជាដីកសិកម្ម ។ ការធ្វើអប្បរមាកម្ម រឺកាត់បន្ថយផលប៉ះពាល់ដែលមានសក្តានុពលនឹងទាមទារនូវការអភិវឌ្ឍគោលនយោបាយនិងនិតិវិធីរបស់រដ្ឋាភិបាលសំរាប់ការចាត់ចំណាត់ថ្នាក់ដី ពង្រឹងផែនការប្រើប្រាស់ដី និងពង្រឹងច្បាប់បរិស្ថាន ហើយនិងអនុក្រិតរបស់វា រាប់បញ្ចូលទាំងការវាយតំលៃលើផលប៉ះពាល់ដល់បរិស្ថាន ។ វាក៏នឹងតំរូវអោយកសាងសមត្ថភាពរបស់ក្រសួងបរិស្ថានផងដែរ ដើម្បីអោយក្រសួងមានលទ្ធភាពអាចប្រតិបត្តិច្បាប់ និងបទបញ្ញាស្តីអំពីការការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិអោយបានល្អប្រសើរ ។

១១. ទិដ្ឋភាពសង្គម**ការវាយតំលៃសង្គមៈ  រដ្ឋាភិបាលកម្ពុជា បានចាប់ប្រតិបត្តិរបៀបវារៈកំណែទំរង់ដើម្បីរៀបចំជំរុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចប្រកបដោយចិរភាព ជំរុញការកាត់បន្ថយភាពក្រីក្រ** និងធ្វើអោយមានសន្តិភាព ។ ក្របខ័ណ្ឌគោល នយោបាយដី គឺជាគំនិតផ្តួចផ្តើមមួយក្នុងចំណោមគំនិតផ្តួចផ្តើមសំខាន់ៗបំផុតជាច្រើន និងរាប់បញ្ចូលទាំងការផ្តល់ ប័ណ្ណសំគាល់កម្មសិទ្ធិដែលមានល្បឿនលឿន ការបង្កើតក្របខ័ណ្ឌស្របច្បាប់សំរាប់គ្រប់គ្រងសិទ្ធិអចលនទ្រព្យ និង បង្កើតនូវផែនការមេសំរាប់អាណាខេត្ត និងច្បាប់នគរូបនីយកម្ម ។ តាមស្ថានការណ៏នៃកម្មវិធីផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិ ការវាយតំលៃសង្គមមួយត្រូវបានគេធ្វើឡើងក្នុងអំឡុងពេលរៀបចំគំរោង ។ គោលដៅចំបងនានានៃការវាយតំលៃ សង្គមនោះគឺដើម្បី (១) បញ្ជាក់អោយបានច្បាស់អំពីសមាជិកផ្សេងៗគ្នាដែលមានចំណែកក្នុងគំរោងនិងដី (២) ពិនិត្យសមត្ថភាពរបស់ស្ថាបន្សនិងសង្គមនៅថ្នាក់មូលដ្ឋាន ចំពោះសិទ្ធិកាន់កាប់ដី (៣) ព្យាករណ៏ទុកលើផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានឡើងរបស់កម្មវិធី និង(៤) ធ្វើអនុសាសន៏លើគោលនយោបាយដែលទាក់ទង ។ ការសិក្សានេះមានគុណភាព ហើយត្រូវបានគេធ្វើឡើងនៅក្នុងខេត្តចំនួន ៥ ក៏ដូចជាការសិក្សាអំពីការអភិវឌ្ឍនៅទីក្រុងភ្នំពេញដែលផ្តោតការយកចិត្តទុកដាក់លើការតាំងទីលំនៅខុសច្បាប់ ។ វិធីសាស្ត្រដែលមានគុណភាពផ្សេងៗទៀត ត្រូវបានគេប្រើប្រាស់ ដូចជា ការពិភាក្សាជាក្រុមតូចៗ និងការសំភាសន៏ជាបុគ្គលជាមួយកសិករ អ្នកផ្លាស់ទីលំនៅ ទាហានរំសាយ ក្រុមស្ត្រី

និងមន្ត្រីមូលដ្ឋាន ។ ក្រុមស្រាវជ្រាវក៏បានសំភាសន៏ បុគ្គលិកមកពីនាយកដ្ឋានគ្រប់គ្រងដីធ្លីនៅថ្នាក់ស្រុកនិងខេត្ត គណកម្មាការដោះស្រាយជំលោះ
ដីធ្លីខេត្ត ប្រធានចៅក្រមតុលាការខេត្ត មន្ត្រីនាយកដ្ឋានពន្ធដារព្រមទាំងប្រធានភូមិ មេឃុំ និងចៅហ្វាយស្រុក ។ នៅភ្នំពេញ សិក្ខាសាលាដែលមានរយៈពេលពេញមួយថ្ងៃ នៅខែ កុម្ភៈ ឆ្នាំ ២០០១ ដែលចូលរួមដោយមន្ត្រីក្រុង និងអង្គការក្រៅរដ្ឋាភិបាលត្រូវបានរៀបចំឡើងដើម្បីចំរាញ់យកពតិមានស្តីអំពីបញ្ហាដីនៅ ក្នុងទីក្រុង ។ លទ្ធផលនិងការវិភាគចុងក្រោយរបស់ វា ត្រូវបានគេបង្ហាញនៅឯសិក្ខាសាលារបស់សមាជិកដែលមាន ចំណែកក្នុងគំរោងនៅថ្ងៃទី៩ ខែកក្កដាឆ្នាំ២០០១ ដែលឧបត្ថម្ភដោយក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងវិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៏កម្ពុជា ។ អ្នកចូលរួមមានមកពីអង្គការក្រៅរដ្ឋាភិបាល ការិយាល័យអភិបាល និង នាយកដ្ឋានដីធ្លីខេត្ត ទាំង២៤ ។ លទ្ធផលសំខាន់ដែលបានមកពី វា បានបង្ហាញអោយឃើញថា
ជំលោះលើបញ្ហាដីធ្លីកំពុងតែកើនឡើង នៅពេលដែលតំលៃដី
កើនឡើង ជាពិសេសនៅក្នុងតំបន់ដែលមានសក្តានុពលសំរាប់ការអភិវឌ្ឍដូចជា ដីដែលនៅក្បែរផ្លូវ និងដី ដែលនៅក្នុងរឺជិតតំបន់ទីក្រុង រឺក៏មជ្ឍមណ្ឌលទីផ្សារ ។ នៅខណៈដែលសហគមនានាទទួលស្គាល់សិទ្ធិកាន់កាប់ដីធ្លីតាម ទំនៀមទំលាប់ប្រពៃណី មានប្រជាជន និងអង្គភាពជាច្រើនដែលមកពីខាងក្រៅសហគមកំពុងប្រកាសទាមទារយក ដីនោះ ដោយសំអាងលើនីតិវិធី និងច្បាប់ផ្លូវការ ។ ការប្រតិបត្តិនៅក្នុងប្រព័ន្ធក្រៅផ្លូវការមួយ ប្រជាជនសាមញ្ញ ច្រើនតែមិនអាចការពារខ្លួនពួកគេបានជោគជ័យដោយការប្រើយន្តការដោះស្រាយជំលោះផ្លូវការ ដោយពឹងផ្អែកលើការ បង្ហាញឯកសារផ្លូវការនោះឡើយ ហើយនិងទាមទារចំណាយប្រាក់ និងពេលវេលា ។ លទ្ធផលនៃការអភិវឌ្ឍសង្គម ជាចំបងមួយរបស់គំរោងគឺត្រូវជួយប្រជាជនចំនួន ១លានគ្រួសារ ភាគច្រើនជាម្ចាស់កម្មសិទ្ធលើទំហំដីតូច១ ពោលគឺ ជួយអោយពួកគេទទួលបានប័ណ្ណសំគាល់កម្មសិទ្ធិដីជាផ្លូវការ ហើយកាត់បន្ថយនូវភាពទទួលការឈឺចាប់ដោយសារគេ បណ្តេញចេញ ។ ដើម្បីធានាអះអាងថា ប្រជាជនក្រីក្រ និងក្រុមតូច១ទទួលបានផលប្រយោជន៏ពេញលេញពីដំណើរ ការនោះ គំរោងនេះនឹងផ្តល់ជំនួយស្របច្បាប់ដល់ប្រជាជនក្រីក្រ ហើយនឹងចុះកិច្ចសន្យាជាមួយអង្គការក្រៅរដ្ឋាភិបាល ដើម្បីអោយធ្វើការនៅក្នុងសហគមនានា និងពាក់ព័ន្ធជាមួយក្រុមគ្រួសារដែលមានសិទ្ធិទាំងអស់ នៅក្នុងកម្មវិធីនេះ ។ ក្រសួងក៏នឹងធ្វើយុទ្ធនាការផ្សព្វផ្សាយពតិមានជាសាធារណៈមួយផងដែរ ដើម្បីពន្យល់អំពីច្បាប់ដីធ្លី បទបញ្ជា និង និតិវិធីថ្មី ។ លទ្ធផល និងអនុសាសន៏សំខាន់១ដែលបានមកពីការវាយតំលៃសង្គម ត្រូវបានគេចុះក្នុងតារាងម៉ាត្រិក នៅចុងបញ្ចប់ នៃឧបសម្ព័ន្ធ ១២ ឯកសារភ្ជាប់លេខ ១ ។
ការវាយតំលៃសង្គមពេញលេញគឺអាចរកបាននៅក្នុងឯកសារគំរោង ។
លទ្ធផលនៃការវាយតំលៃសង្គមនេះត្រូវបានគេប្រើប្រាស់នៅក្នុងការរៀបចំគំរោង ជាពិសេសនៅក្នុងតំបន់ដែលចូលរួម ការបែងពតិមាននិងការអប់រំស្តីអំពីសិទ្ធិដីធ្លី ដំណោះស្រាយជំលោះដីធ្លី និងការសិក្សាគោលនយោបាយក្នុងអនាគត និងគោលការណ៏ណែនាំអនុវត្ត ។ ការតាំងទីលំនៅសារជាថ្មីគំរោងនេះត្រូវបានរៀបចំឡើងដើម្បីចៀសវាង ប៉ះពាល់ជា

អវិជ្ជមានដល់ប្រជាជន ។ ផលប៉ះពាល់ជាអវិជ្ជមានដែលមាន សក្តានុពលលើប្រជាជន គឺទាក់ទងទៅនឹងការ បង្កើតអាគាររដ្ឋបាលដី ។ គំរោងនេះនឹងជួយឧបត្ថម្ភក្នុងការជួសជុល ស្តារឡើងវិញនិង/រឺការសាងសង់ទីកន្លែងការិយាល័យសំរាប់កម្មវិធី ។ មានជំរើសពីរសំរាប់ការទទួលយកដី នៅក្នុង ករណីនៃការសាងសង់ទីកន្លែងការិយាល័យថ្មី ។ ជំរើសទី ១ និងជំរើសដែលគេពេញចិត្តជាងគឺ ត្រូវសាងសង់អាគារនានា នៅលើដីសាធារណៈដែលនៅទំនេរ ដើម្បីចៀសវាងផលប៉ះពាល់អវិជ្ជមានណាមួយ ។ ជំរើសទីពីរ ប្រសិនបើរដ្ឋាភិបាល មិនអាចសាងសង់អាគារនានា នៅលើដីសាធារណៈដែលនៅទំនេរនោះបានទេ រដ្ឋាភិបាលត្រូវតែប្រើរបាស់ដីសាធារណ ដទៃទៀតដែលក្នុងករណីនោះ វាអាចនឹងប៉ះពាល់ដល់លំនៅដ្ឋានរបស់ប្រជាជន ។ ក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅ សាជាថ្មីដែលបានឯកភាពរួច នឹងត្រូវអនុវត្ត ប្រសិនបើជំរើសទីពីរត្រូវបានគេប្រើប្រាស់ ។

កិច្ចព្រមព្រៀងត្រូវបានសំរេចជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម ដែលទាក់ទងទៅនឹងរបៀបដោះស្រាយនានា ដែលនឹងត្រូវយកមកប្រើប្រាស់ក្នុងការដោះស្រាយរឿងក្តីរបស់អ្នកតាំងទីលំនៅក្រៅផ្លូវការ រាប់បញ្ចូលទាំងអ្នកតាំងទីលំនៅខុសច្បាប់ផង ។ គំរោង (ក) នឹងផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិ ដែលមានការព្រមព្រៀងពីរដ្ឋាភិបាលក្នុងការផ្តល់ដី ដែលនឹងត្រូវចុះក្នុងបញ្ជីទៅអោយអ្នកតាំងទីលំនៅក្រៅផ្លូវការ (ខ) នឹងសំរួលដល់ការផ្តល់សេវាកម្ម និងផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិដែលសាលាក្រុងកំពុងតែធ្វើការជាមួយនិងមជ្ឈមណ្ឌលសំរាប់ការតាំងទីលំនៅរបស់មនុស្ស របស់សហប្រជាជាតិ ១ូណជះ្យច និងដៃគូរបស់ខ្លួន ដើម្បីផ្តល់ដីទៅអោយអ្នកតាំងទីលំនៅក្រៅផ្លូវការ តាមរយៈការបែងចែកដី និង/រឺកម្មវិធីបោះទីតាំងសាជាថ្មី និង(គ) នឹងមិនចេញប័ណ្ណសំគាល់កម្មសិទ្ធិដែលគ្មានការព្រមព្រៀងក្នុងការបែង ចែកដីទៅអោយអ្នកតាំងទីលំនៅក្រៅផ្លូវការ ឬតាមរយៈការបែងចែកដីរបស់សាលាក្រុង ឬ្ហណជះ្យ និង/រឺតាម រយៈកម្មវិធីបោះទីតាំងសាជាថ្មី ។ កម្មវិធីរបស់្ូណជះ្យ មានមូលដ្ឋាន ផ្អែកលើគោលការណ៍អន្តរជាតិសំរាប់ការ ជ្រកកោនគឺៈ ក) ផ្តល់សន្តិសុខកាន់កាប់ ខ)ជំរុញអោយមានសិទ្ធិទទួលបានទីលំនៅគ្រប់គ្រាន់  គ) ផ្តល់សិទ្ធិ រឺឱកាសស្មើភាពគ្នាក្នុងការទទួលយកដី ឃ)ជំរុញអោយសិទ្ធិរឺឱកាសស្មើភាពក្នុងការទទួលយកជំនឿ និង ង)ជំរុញអោយមានសិទ្ធិរឺឱកាសទទួលបាននូវគោលការណ៍ណែនាំនិងសេវាកម្មជាមូលដ្ឋាន ។ គំរោងនេះ នឹងអភិវឌ្ឍនិតិវិធីសំរាប់ត្រួតពិនិត្យ និងពិគ្រោះយោបល់ ដើម្បីធានាអះអាងថា លក្ខ័ណ្ឌនានាខាងលើត្រូវបានគេយល់ព្រមមុនការផ្តល់ការចុះបញ្ជីដី និងសេវាកម្មផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិ ។ ដោយគំរោងនេះនឹងផ្តល់ហិរញ្ញប្បទានសំរាប់ការសាងសង់អាគារការិយាល័យថ្មីមួយ សំរាប់ក្រសួង និងការស្តារឡើងវិញ ឬការសាងសង់ថ្មីនូវការិយាល័យនានានៅលើដីរបស់ស្រុកនិងខេត្ត គេបានយល់ព្រមជាមួយរដ្ឋាភិបាលថា ការិយាល័យទាំងនេះ នឹងត្រូវកសាងឡើងនៅលើដីសាធារណៈដែលនៅទំនេរ ដូច្នេះហើយ បានជាការតាំងទីលំនៅថ្មីនឹងមិនត្រូវបានពាក់ព័ន្ធ ។

ជនជាតិភាគតិចអន្តោគ្រាម

តំបន់ដែលស្ថិតនៅក្នុងគំរោង (ដំណាក់កាលដំបូងនៃកម្មវិធីរយៈពេលវែង) ដែលមាន ១០ខេត្ត និងក្រុងភ្នំពេញ ត្រូវបានស្នើឡើងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យយល់ស្រប ។ តំបន់ទាំងនោះមិនរាប់បញ្ចូលខេត្តនានានៅក្នុងភាគឥសានទេ ដែលជាកន្លែងជនជាតិភាគតិចអន្តោគ្រាមរស់នៅ ។ នៅក្នុងការសង្ឃឹមទុកជាមុន ក្នុងការបញ្ចូលតំបន់ភាគឥសានចូលទៅក្នុងតំណាក់កាលទីពីរនៃកម្មវិធី ការពិនិត្យឡើងវិញមួយ និងការធ្វើពង្រៀងនៃគោលការណ៍ណែនាំអនុវត្តសំរាប់ចុះបញ្ជីសំគាល់សិទ្ធិដីរបស់ជនជាតិភាគតិចអន្តោគ្រាម និងឃុំ នឹងត្រូវបានគេធ្វើឡើងនៅក្នុងដំណាក់កាលទី១ ។ គោលការណ៍ណែនាំអនុវត្តន៏ និងការពិនិត្យឡើងវិញដែលបានដាក់ស្នើឡើងសំរាប់ដីដែលត្រូវផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិអោយជនជាតិភាគតិចអន្តោគ្រាម នឹងចាត់ទុកថាជាមូលដ្ឋានគ្រឹះនៃគោលនយោបាយដែលមាននៅក្នុងពង្រៀងច្បាប់ដីធ្លីឆ្នាំ ២០០១ និងមេរៀននានាដែលបានសិក្សាពីគំរោងទាំងឡាយដែលកំពុងអនុវត្តសំរាប់សហគមអន្តោគ្រាមនៅក្នុងតំបន់ភាគឥសាន ។

១១. ចំនុចទាក់ទង: ប្រធានក្រុមការងារ Wael Zakout


ធនាគារពិភពលោក

1818 H Street, NW

Washington D.C. 20433

Telephone: 202 473 3537

Fax: 202 477 2733


១២. ចំពោះពត៌មានស្តីអំពីឯកសារដែលពាក់ព័ន្ធទៅនឹងគំរោងដទៃៗទៀតសូមទាក់ទង: The Infoshop


ធនាគារពិភពលោក

1818 H Street. NW

Washington D.C. 20433

Telephone: (202) 458-5454

Fax: (202) 522-1500

Web: http:// www.worldbank.org/infoshop


សំគាល់: នេះជាពត៌មានស្តីអំពីការវិវត្តន៏នៃគំរោង ។ សមាសភាគមួយចំនួនអាចមិនចាំបាច់ដាក់បញ្ចូលនៅក្នុងគំរោងចុងក្រោយ ។


របាយការណ៏នេះរៀបរៀងដោយ InfoShop នៅថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០០១ ។